គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA

# របាយការណ៍

## ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖ សភា និងតំណាងរាស្ត្រស្ត្រី និងស្ត្រី ក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦



ខែមីនា ឆ្នាំ២០១៧

# របាយការណ៍

## ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖

## សភា និងតំណាងរាស្ត្រស្ត្រី និងស្ត្រីក្នុងដំណើរការចុះ

## ឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦

# មាតិកា


បុព្វកថា ..... 3

I. សេចក្តីផ្តើម ..... 5

II. ការឃ្លាំមើលសភា និងតំណាងរាស្ត្រស្ត្រី ..... 9

១. សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន ..... 9

- តារាងទី១៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី-បុរស ..... 9
- ១.១. ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី ..... 11
- តារាងទី២៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី ..... 11
- តារាងទី៣៖ ចំនួនតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្របុរសដែលបានចុះបេសកកម្មគិតជាភាគរយ ..... 12
- តារាងទី៤៖ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្របុរសនៃគណបក្សនីមួយៗ ..... 13
- តារាងទី៥៖ តំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មច្រើនជាងគេ ..... 14

២. សភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី (Women Parliamentarian Caucus)សមាជិការដ្ឋសភា ..... 14

III. ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ ..... 16

IV. ស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ..... 17

១. ព័ត៌មាន និងស្ថានភាពឃុំ សង្កាត់ ..... 19

១.១. អំពីសន្តិសុខ សុវត្ថិភាព និងការភ័យខ្លាចនៅក្នុងឃុំ សង្កាត់ ..... 19

១. ២. ស្ថានភាពគណបក្សនយោបាយ ..... 19

២. ព័ត៌មានស្តីពីការចុះឈ្មោះបោះឆ្នោត ..... 20

២. ១. ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោតប្រចាំឃុំ សង្កាត់ (កចប) ..... 20

២. ២. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ..... 21

ក. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ ..... 21
ខ. ស្ត្រីក្រុមប្រឹក្សាឃុំសង្កាត់មិនប្រចាំការ ..... 21
២. ៣. អំពីការចុះឈ្មោះបោះឆ្នោត..... 22
ក. ស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត ..... 22
ខ. ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត ..... 23
២. ៤. ស្ត្រីជាអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ ..... 24
២. ៥. ភាពមិនប្រក្រតីក្នុងដំណើរការចុះឈ្មោះបោះឆ្នោត..... 24
២. ៦. ការអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោត ..... 25
**៣. ចំនួនស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦** ..... 30
៣. ១. ស្ត្រីបានចុះឈ្មោះបោះឆ្នោត ..... 30
៣. ២. ស្ត្រីជាអ្នកសង្កេតការណ៍ចុះឈ្មោះបោះឆ្នោត..... 30
៣. ៣. ស្ត្រីជាភ្នាក់ងារគណបក្សសម្រាប់សង្កេតការណ៍ពេលចុះឈ្មោះបោះឆ្នោត..... 31
៣. ៤. ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត ..... 31
**V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ..... 32
**ផ្នែកឧបសម្ព័ន្ធ**

## បុព្វកថា៖

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា** ហៅកាត់ថា "**ខុមហ្វ្រែល**" ធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋតាមគោលការណ៍ កសាងសមត្ថភាពរបស់បណ្តាញទូទាំងប្រទេស និងសហប្រតិបត្តិការជាមួយអង្គការជាសមាជិក និងជាដៃគូ ។ ប្រជាធិបតេយ្យមិនមែនត្រឹមតែការបោះឆ្នោតប៉ុណ្ណោះទេ ក៏ប៉ុន្តែជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ជាលក្ខខណ្ឌចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ ។ បន្ថែមពីលើនេះទៀត ការមានគណនេយ្យភាពរបស់គណបក្សជាប់ឆ្នោត និងមន្រ្តីជាប់ឆ្នោតក្នុងការបំពេញតាមការសន្យារបស់ខ្លួន ការលើកស្ទួយ ការការពារការចូលរួមក្នុងការសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ ការបំពេញនូវតួនាទី ភារកិច្ច និងការទទួលបានសិទ្ធិអំណាចពេញលេញរបស់ស្រ្តី គឺជារឿងសំខាន់បំផុតក្នុងអភិក្រមប្រជាធិបតេយ្យ ។

របាយការណ៍ស្តីពី « **ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ ៖ សភា និងតំណាងរាស្រ្តស្រ្តី និងស្រ្តីក្នុងដំណើរការចុះឈ្មោះថ្មី ឆ្នាំ២០១៦** » គឺជាទម្រង់នៃការវិភាគទៅលើទិន្នន័យ និងមតិយោបល់របស់តំណាងជាប់ឆ្នោតស្រ្តីចូលរួមក្នុងកិច្ចការនយោបាយ និងក្នុងដំណើរការសម្រេចចិត្ត ជាពិសេស ការតាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់តំណាងជាប់ឆ្នោតស្រ្តីថ្នាក់ជាតិ និងការចូលរួមនយោបាយរបស់ស្រ្តីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ និងផលប៉ះពាល់មកលើស្រ្តី ។

របាយការណ៍នេះ បង្ហាញការវាយតម្លៃលើការផ្តល់អំណាចឲ្យតំណាងរាស្រ្តស្រ្តីក្នុងអំឡុងពេលបំពេញការងារទាក់ទងនឹងសកម្មភាព និងគោលបំណងរបស់អ្នកតំណាងរាស្រ្តស្រ្តីចុះមូលដ្ឋានតាមមណ្ឌលខេត្ត ក្រុងនានា ចំនួនតំណាងរាស្រ្តស្រ្តីធៀបនឹងតំណាងរាស្រ្តបុរសដែលបានចុះបេសកកម្ម ភាគរយអ្នកតំណាងរាស្រ្តស្រ្តីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្រ្តបុរសនៃគណបក្សនីមួយៗ និងសកម្មភាពរបស់សភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្រ្តីទាក់ទងនឹងកិច្ចការស្រ្តី និងកុមារ ។ បន្ថែមលើនេះទៀត របាយការណ៍នេះក៏បានបង្ហាញផងដែរ អំពីការបំពេញការងាររបស់រាជរដ្ឋាភិបាលទាក់ទងនឹងកម្មវិធីនយោបាយស្តីពីបញ្ហាស្រ្តី និងកុមារ និងក៏បានបង្ហាញនូវលទ្ធផលនៃការសិក្សាអំពី ការចូលរួមនយោបាយរបស់ស្រ្តីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ និងផលប៉ះពាល់មកស្រ្តីផងដែរ។

**ខុមហ្វ្រែល**សង្ឃឹមថា **របាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយ**នេះ ជាឯកសារដ៏សំខាន់ និងមានប្រយោជន៍សម្រាប់អ្នកអនុវត្តន៍សកម្មភាព ជាពិសេស**មន្រ្តីរដ្ឋាភិបាល សមាជិកសភា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយ បុគ្គលិកសមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងរបស់ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ ដើម្បីជួយលើកស្ទួយស្រ្តីចូលរួមកាន់តែច្រើនក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត** ។

សូមថ្លែងអំណរគុណជាពិសេសចំពោះក្រុមការងាររបស់ខុមហ្វ្រែល ដូចជា លោកស្រី **សឺនកេត សិរីលក្ខណ៍** ដែលជាអ្នកសរសេររបាយការណ៍នេះ ។ លោកស្រីក៏ជាអ្នកដឹកនាំក្រុមការងារ ដូចជា លោក **នាង សុវណ្ណ** និង**អ្នកសង្កេត**

**ការណ៍ស្ត្រី** ដែលខិតខំអនុវត្តតាមផែនការសកម្មភាពដើម្បីប្រមូលទិន្នន័យ និងកញ្ញា **ជូ សុភ័ក្រ**ដែលជាអ្នករចនារបាយការណ៍នេះ ដោយមានការគាំទ្រពីក្រុមការងាររបស់ខុម**ហ្វ្រែល ផ្នែកអង្កេត** និង**លេខាធិការខុមហ្វ្រែលទាំង២៥ខេត្ត ក្រុង រាជធានី** ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោក គល់ បញ្ញា និងលោក គីម ឈនផងដែរ ដែលបានផ្តល់មតិយោបល់ល្អៗធ្វើឲ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរថែមទៀត ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧

**នាយកប្រតិបត្តិខុមហ្វ្រែល**

**គល់ បញ្ញា**

## I. សេចក្តីផ្តើម

យោងតាមលទ្ធផលនៃការអនុវត្តន៍ការងារលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជា និងផ្អែកតាមការសិក្សាស្រាវជ្រាវនៅក្នុងពិភពលោក ភស្តុតាងមួយចំនួនបានបង្ហាញយ៉ាងច្បាស់ថា ការចូលរួម**ស្របច្បាប់ និងពេញលេញ**របស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចអាចធ្វើឲ្យគោលនយោបាយ ច្បាប់ និងកម្មវិធីនានាកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនទាំងអស់ ជាពិសេសលើបញ្ហាសុខុមាលភាពគ្រួសារ និងសង្គមដែលជាមូលដ្ឋានគ្រឹះក្នុងការកាត់បន្ថយភាពក្រីក្រឈានឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព[1] ។

ដូច្នេះ ការសង្កេត តាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់តំណាងស្ត្រីជាប់ឆ្នោតថ្នាក់ជាតិ និងការចូលរួមនយោបាយរបស់ស្ត្រី និងផលប៉ះពាល់មកលើស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ គឺជារបៀបវារៈសំខាន់បំផុតដែលត្រូវស្វែងយល់ និងឃ្លាំមើលដោយយកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធ ប្រយោជន៍លើកស្ទួយ ការពារការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ រួមទាំងការទទួលបាននូវសិទ្ធិអំណាចពេញលេញរបស់ស្ត្រីផងដែរ ។

របាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយរបស់ខុមហ្វ្រែលប្រចាំឆ្នាំ២០១៦នេះ ត្រូវបានធ្វើឡើងតាមវិធីសាស្រ្តសង្កេតការណ៍ដោយផ្ទាល់ តាមដាន ការសម្ភាសន៍តាមបែបសំណេះសំណាល (Semi-Interview) ការសម្ភាសន៍ផ្ទាល់ (Interview) និងការពិនិត្យមើលលើស្ថានភាព និងការងាររបស់តំណាងស្ត្រីជាប់ឆ្នោតថ្នាក់ជាតិ ការបំពេញការងាររបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងកម្មវិធីនយោបាយស្តីពីបញ្ហាស្ត្រី និងកុមារ និងការចូលរួមនយោបាយរបស់ស្ត្រី និងផលប៉ះពាល់មកលើស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ដោយផ្អែកលើការប្រមូលទិន្នន័យបែបគុណភាព ។

សំណួរចំបង គឺ *តើស្ត្រីជាប់ឆ្នោតទាំងនោះធ្វើការបានលទ្ធផលយ៉ាងណាខ្លះ? តើអ្នកតំណាងរាស្ត្រស្ត្រី និងបុរសបានចុះមូលដ្ឋានកម្រិតណា? ក្នុងគោលបំណងអ្វីខ្លះ? តើក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រីក្នុងឆ្នាំ២០១៦បានធ្វើសកម្មភាពការងារអ្វីខ្លះទាក់ទងនឹងស្ត្រី និងកុមារ? តើម្ចាស់ឆ្នោតពេញចិត្តនឹងការបំពេញ និងអនុវត្តកម្មវិធីនយោបាយរបស់រដ្ឋាភិបាលកម្ពុជាទាក់ទងនឹងបញ្ហាស្ត្រី និងកុមារដែរឬទេ? អំពីការចូលរួមនយោបាយរបស់ស្ត្រីក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦យ៉ាងដូចម្តេចខ្លះ? ហើយមានផលប៉ះពាល់មកលើស្ត្រីអ្វីខ្លះ?*

---

[1] សុន្ទរកថារបស់លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយសភា ព្រឹទ្ធសភា និងអធិការកិច្ចក្នុងពិធីបើកវេទិកា ជាតិ ស្តីពី «ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ» នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

### *សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន*

សម្រាប់ឆ្នាំទី៣ នីតិកាលទី៥នៃរដ្ឋសភា ឆ្នាំ២០១៦ មានគណបក្សនយោបាយចំនួនពីរជាប់ឆ្នោត មានអាសនៈនៅក្នុងរដ្ឋសភាជាតិគឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ។

តាមទិន្នន័យទទួលបានពីអ្នកសង្កេតការណ៍ខុមហ្វ្រែល បង្ហាញថា សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងរយៈពេលចាប់ពីខែមករា រហូតដល់ ខែធ្នូ ឆ្នាំ២០១៦ មានតំណាងរាស្ត្រចំនួន**៩៨នាក់**ក្នុងចំណោមតំណាងរាស្ត្រសរុប ១២៣នាក់ (តំណាងរាស្ត្រ៥៤នាក់មកពីគណបក្សប្រជាជនកម្ពុជា មាន**ស្ត្រី១៧នាក់** និងតំណាងរាស្ត្រ៤៤នាក់មកពីគណបក្សសង្គ្រោះជាតិ មាន**ស្ត្រី៣នាក់**) បានចុះមូលដ្ឋានសរុបចំនួន**១៦៦៥លើក ឆ្នាំ២០១៦** (គណបក្សប្រជាជនកម្ពុជាចំនួន ៥៦៤លើក ស្មើនឹង ៣៣,៨៧% និងគណបក្សសង្គ្រោះជាតិចំនួន ១១០១លើក ស្មើនឹង ៦១,១៣%) ។ ចំនួននេះបាន**កើនឡើង**ចំនួន **៥៥៨លើក** គឺពី **១១០៧លើក** ឆ្នាំ២០១៥ មកដល់ **១៦៦៥លើក** ឆ្នាំ២០១៦ ។

*ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះមូលដ្ឋាន/បេសកកម្ម ច្រើនជាងភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះមូលដ្ឋាន* គឺ ៨៣,៣៣% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី២០នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៤នាក់ ច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន ៧៨,៧៩% ស្មើនឹង៧៨នាក់ក្នុងចំណោមសមាជិកសភាបុរស ៩៩នាក់ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ភាគរយរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម**បានកើនឡើង** ពី៧០,៨៣%ឆ្នាំ២០១៥ ទៅ ៨៣,៣៣%ឆ្នាំ២០១៦ ខណៈដែលអ្នកតំណាងរាស្ត្របុរសចុះបេសកកម្មក៏មានការ**កើនឡើងដែរ** គឺពី ៧៧,៧៧%ឆ្នាំ២០១៥ ទៅ ៧៨,៧៩%ឆ្នាំ២០១៦ ។

ក្នុងរយៈពេលនេះអ្នកតំណាងរាស្ត្រស្ត្រីទាំង២០នាក់នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភាបានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន **៣៣៩លើក** ក្នុងនោះ *ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានចំនួន២២១លើក ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន២៩លើក ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សចំនួន៧១លើក និងការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិលចំនួន៥លើក ព្រមទាំងការអន្តរាគមន៍ និងដោះស្រាយបញ្ហានានាមាន១៣លើក* ។ ចំនួនសកម្មភាពនេះមានការ**កើនឡើង**ចំនួន **៨៩លើក** ពី **២៥០លើក** ឆ្នាំ២០១៥ ទៅ **៣៣៩លើក** ឆ្នាំ២០១៦ ។

បើប្រៀបធៀប ពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការ**ខុសគ្នាឆ្ងាយ**រវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន**២២១លើក (៦៥,១៩%)** ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋមានចំនួនតែ **១៣លើក (៣,៨៣%)**ប៉ុណ្ណោះ។* តួលេខនេះ នៅតែបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះ*

*សំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានានៅតែជាសកម្មភាពអាទិភាព និងសកម្មដដែល ដោយមានការ**កើនឡើងចំនួន២៤លើក** ពី ១៩៧លើកឆ្នាំ២០១៥ ទៅ ២២១លើកឆ្នាំ២០១៦ ខណៈដែលនៅតែមានភាពមិនសូវសកម្មដដែលក្នុងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ បើទោះបីមានការ**កើនឡើងតិចតួច**ក៏ដោយ ពី ៧លើកឆ្នាំ២០១៥ ទៅ១៣លើកឆ្នាំ២០១៦ ។*

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានក្នុងឆ្នាំ២០១៦ តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន **ច្រើនជាង** តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។ ជាក់ស្តែង តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចំនួន១៧នាក់ បានខិតខំធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួន**២២០លើក** គឺមានការ**កើនឡើងស្ទើរតែបីដង** បើធៀបនឹងឆ្នាំ២០១៥មានតែចំនួន១២នាក់បានធ្វើសកម្មភាពនៅមូលដ្ឋានចំនួនតែ៨៥លើកប៉ុណ្ណោះ ។ ចំណែកឯ តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិចំនួន៣នាក់ ក៏បានខិតខំធ្វើសកម្មភាពនៅមូលដ្ឋានដែរចំនួន១១៩លើកក្នុងឆ្នាំ២០១៦ ប៉ុន្តែមានការ**ថយចុះ**បើធៀបនឹងឆ្នាំ២០១៥ មានចំនួន៥នាក់បាន១៦៥លើកឯណោះ ។

ទោះបីជាយ៉ាងណាក៏ដោយ បើគិតជាមធ្យមភាគនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រីម្នាក់ៗ រកឃើញថា *អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ **មានភាពសកម្មជាង** អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា* ។ ជាក់ស្តែង អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិក្នុង១នាក់ បានចុះមូលដ្ឋានប្រមាណ**៤០លើក** (៣នាក់ ចំនួន១១៩លើក) រីឯ អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាក្នុង១នាក់បានចុះមូលដ្ឋានប្រមាណតែ **១៣លើក** (១៧នាក់ ចំនួន២២០លើក)ប៉ុណ្ណោះ ។

ដោយធ្វើការប្រៀបធៀបនៅក្នុងគណបក្ស ភាគរយអ្នកតំណាងរាស្ត្រស្ត្រី**មកពីគណបក្សប្រជាជនកម្ពុជា** បានចុះបេសកកម្មមានចំនួន **១០០%** (១៧នាក់ក្នុងចំណោម១៧នាក់) **ច្រើនជាង** ភាគរយអ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលមានចំនួនតែ**៧២,៥៥%** (៣៧នាក់ក្នុងចំណោម៥១នាក់) ប៉ុណ្ណោះ ។ បន្ថែមលើនេះទៀត បើប្រៀបធៀបនឹងឆ្នាំ២០១៥ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋានមានការ **កើនឡើងដល់ចំណុចកំពូល** គឺពី ៧០,៥៩% ឆ្នាំ២០១៥ ទៅដល់ ១០០% ឆ្នាំ២០១៦ ។ រីឯភាគរយអ្នកតំណាងរាស្ត្របុរសក៏មានការ**កើនឡើងដែរ** ពី ៥៨,៨២% ឆ្នាំ២០១៥ ទៅ ៧២,៥៥%ឆ្នាំ២០១៦ ។

ដោយឡែក ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ **តិចជាង** ភាគរយអ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលបានចុះបេសកកម្ម គឺភាគរយស្ត្រីស្មើនឹង **៤២,៨៦%** (៣នាក់ ក្នុងចំណោម៧នាក់) និងភាគរយបុរសមានចំនួន **៨៥,៤២%** (៤១នាក់ក្នុងចំណោម៤៨នាក់) ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន **បន្តថយចុះខ្លាំង** ពី ៨៥,៧១%ឆ្នាំ២០១៤ មកត្រឹម ៧១,៤៣%ឆ្នាំ២០១៥ រហូតមកត្រឹម

៩២,៨៦%ឆ្នាំ២០១៦ ខណៈដែលភាគរយអ្នកតំណាងរាស្ត្រប្រុសក៏មានការ**ថយចុះ**ដែរ ពី៩៧,៩២% ឆ្នាំ២០១៥ មកត្រឹម ៨៥,៩២% ឆ្នាំ២០១៦ ។

### *ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ*

យោងតាមរបាយការណ៍ឃ្លាំមើលរដ្ឋាភិបាល អាណត្តិទី៥របស់ខុមហ្វ្រែល ម្ចាស់ឆ្នោតចំនួន១៨រាជធានី ខេត្តបាន ផ្តល់ពិន្ទុរទៅលើការបំពេញកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំទី៣ ក្នុងឆ្នាំ២០១៦ ទាក់ទងនឹង *«ការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួលបានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋាន»* ។ ជាលទ្ធផលបង្ហាញថា *ឆ្នាំ២០១៦គឺជាឆ្នាំគួរឲ្យភ្ញាក់ផ្អើល ដែលម្ចាស់ឆ្នោតបានផ្តល់ពិន្ទុគាំទ្រខ្ពស់បំផុតទាក់ទងនឹងការបំពេញកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល* ។ ជាក់ស្តែង បើប្រៀបធៀបនឹងឆ្នាំ២០១៥ ម្ចាស់ឆ្នោតបានផ្តល់ភាគរយខ្ពស់បំផុតក្នុងការ**ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង**ដែលមានចំនួនចន្លោះពី ៨០% ទៅ ១០០%ឆ្នាំ២០១៦ ដែលខុសគ្នាដាច់ស្រឡះពីឆ្នាំ២០១៥ដែលជាភាគរយទាបបំផុត គឺ ៨,១៩% គឺ**កើនឡើងខ្លាំងប្រមាណជាង ៨០%** ខណៈដែលម្ចាស់ឆ្នោត***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច***ក៏មានការ**ធ្លាក់ចុះ**ដែរ ពី ២៧,៦៣% ឆ្នាំ២០១៥ មកត្រឹម ចន្លោះពី ០% ទៅ ២០% ឆ្នាំ២០១៦ ។ តួលេខនេះបង្ហាញថា *ការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងកុមារទទួលបានសិទ្ធិជាមូលដ្ឋាន*របស់រាជរដ្ឋាភិបាលកម្ពុជាមានភាព**ប្រសើរជាងមុន** ដែលធ្វើឲ្យម្ចាស់ឆ្នោតចាប់ផ្តើមគាំទ្រ និងពេញចិត្ត ។

### *ស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦*

**ស្ត្រីបានចុះឈ្មោះបោះឆ្នោតថ្មី** ឆ្នាំ២០១៦ក្នុងបញ្ជីបោះឆ្នោតផ្លូវការ ចំនួន **៤ ២១០ ៩១៤ នាក់ ស្មើនឹង ៥៣,៥៣%** នៃចំនួនប្រុស-ស្រីដែលបានចុះឈ្មោះសរុប **៧ ៨៦៥ ០៣៣នាក់** ហើយក៏មិនមានករណីមិនប្រក្រតីណាមួយមកលើស្ត្រីក្នុងការចូលរួមនយោបាយក្នុងដំណើរការចុះឈ្មោះបោះឆ្នោតនេះដែរ ។

ប៉ុន្តែ មានការ**ខកខានប្រើប្រាស់សិទ្ធិរបស់ខ្លួន**ក្នុងការចុះឈ្មោះបោះឆ្នោត ជាពិសេស ពិរុទ្ធជន និងកម្មករកម្មការិនីចំណាកស្រុកទៅក្រៅប្រទេសដែលមិនមាននីតិវិធីសម្របសម្រួលណាមួយ ឲ្យពួកគាត់បានអនុវត្តសិទ្ធិរបស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញដែលបានធានាអំពីសិទ្ធិនេះ ។

**ស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត** បានបង្ហាញហេតុផលមួយចំនួនថា *«ពួកគេទៅចុះឈ្មោះបោះឆ្នោតគឺ ដើម្បីប្រទេសជាតិ ចង់ឲ្យបក្សដែលខ្លួនស្រឡាញ់បានឈ្នះ អភិវឌ្ឍន៍ក្នុងឃុំ សង្កាត់ បំពេញកាតព្វកិច្ចជាពលរដ្ឋ សម្លេងឆ្នោតរបស់ខ្លួនគឺសំខាន់ក្នុងការជ្រើសរើសតំណាងល្អ»* ។ ស្ត្រីដែលបានចុះឈ្មោះបោះឆ្នោតបានបញ្ជាក់ទៀតថា ដំណើរការចុះឈ្មោះបោះឆ្នោតថ្មីនេះ មានភាពងាយស្រួលដូចជា មិនរង់ចាំយូរ គ្មានការគំរាមកំហែង មានការយកចិត្តទុកដាក់ជួយ

សម្រួលពីមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត ទីកន្លែងធំទូលាយ មិនរញ៉េរញ៉ៃដោយមានប៉ូលីសនៅចាំជួយអន្តរាគមន៍ នៅខាងក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ។

ចំណែកឯ **ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត** បានបង្ហាញពីហេតុផលរបស់ខ្លួនថា « *បាត់/គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយគ្មានសំបុត្រកំណើត ខ្លួនមានអាយុច្រើន គិតថាពិបាកក្នុងការទៅចុះឈ្មោះ ។ ខ្លះទៀត រវល់នឹងកិច្ចការងារ មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ទីទាល់ក្រ ជាជនទុរគត មិនមានឯកសារអ្វីទាំងអស់ ។ អ្នកខ្លះទៀត អស់ជំនឿគ្មានការរីកចំរើនអ្វីសោះក្នុងឃុំរបស់ខ្លួន ។ល។ និង ។ល។* »

**៣៨%នៃស្ត្រីដែលជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត**ភាគច្រើនបានទទួលតួនាទីត្រឹមតែជា**ការីកុំព្យូទ័រ និងជំនួយការប្រធាន**ប៉ុណ្ណោះ ។ **៤៦,៦៦%ជាស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ**ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោតថ្មីនេះនៅក្នុង ១០ឃុំ សង្កាត់ដែលជាតំបន់គោលដៅរបស់ខុមហ្វ្រែល ។

**គ.ជ.បបានខិតខំ**ធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោត**យ៉ាងផុលផុស និងទូលំទូលាយ**ដោយប្រើប្រាស់ឯកសារជាច្រើនប្រភេទ និងវិធីសាស្ត្រផ្សេងៗគ្នានៅទូទាំងប្រទេស ខណៈដែល**២ខែចុងក្រោយ** សកម្មភាពអប់រំផ្សព្វផ្សាយទាំងនេះ**ពុំសូវមានភាពសកម្ម និងមានការថយចុះខ្លាំង** ។ ជាមួយគ្នានេះដែរ **គ.ជ.បបានសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងខិតខំអន្តរាគមន៍ជាមួយអាជ្ញាធរដែនដី** ព្រមទាំងបានផ្គត់ផ្គង់ឯកសារអប់រំមួយចំនួនដល់ក្រុមយុវជនក្នុងយុទ្ធនាការពិសេសអប់រំ ផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែរយៈពេល៣ថ្ងៃ ។ ប៉ុន្តែគួរឲ្យសោកស្តាយ **គ.ជ.បមិនអាចការពារយុទ្ធនាការពិសេសនេះជាមួយការប្រើប្រាស់ឧបករណ៍បំពងសម្លេង**ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត បើទោះបីមានលិខិតអនុញ្ញាតរបស់សាលារាជធានីភ្នំពេញក៏ដោយ ។

# II. ការឃ្លាំមើលសភា និងតំណាងរាស្ត្រស្ត្រី

## ១. សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន

<u>តារាងទី១</u> ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងបុរស

| គោលបំណងនៃការចុះមូលដ្ឋាន | គណបក្សនយោបាយ | |
|---|---|---|
| | ៥៤នាក់ | ៨៤នាក់ |

| ទាំង១៦៦៥លើក របស់អ្នកតំណាងរាស្ត្រ ទាំងស្ត្រី-បុរសចំនួន៩៨នាក់ (ស្រី២០នាក់ ប្រុស៧៨នាក់) | ស្ត្រី ១៧ នាក់ | បុរស ៣៧ នាក់ | ស្ត្រី ៣ នាក់ | បុរស ៤១ នាក់ |
|---|---|---|---|---|

សកម្មភាពទាំង១៦៦៥លើករបស់អ្នកតំណាងរាស្ត្រ ផ្តោតទៅលើចំណុចមួយចំនួនដូចជា៖

- ✧ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា
- ✧ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស
- ✧ការចុះអមដំណើរជាក្រុម ឬ អមដំណើរថ្នាក់ដឹកនាំ
- ✧ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល
- ✧ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ

| សរុបរួម | ៥៦៤លើក ៣៣,៨៧% | ១១០១ លើក ៦១,១៣% |
|---|---|---|

តាមទិន្នន័យទទួលបានពីអ្នកសង្កេតការណ៍ខុមហ្វ្រែល អំពីសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ តាមរយៈការចុះសង្កេតដោយផ្ទាល់ ប្រព័ន្ធផ្សព្វផ្សាយ ការិយាល័យអ្នកតំណាងរាស្ត្រតាមមណ្ឌលខេត្ត និងតាមរយៈស្នាក់ការគណបក្សនយោបាយនៅតាមបណ្តាខេត្តឃើញថា ក្នុងរយៈពេលចាប់ពី ខែមករា រហូតដល់ ខែធ្នូ ឆ្នាំ២០១៦ មានតំណាងរាស្ត្រចំនួន**៩៨នាក់** (៥៤នាក់មកពីគណបក្សប្រជាជនកម្ពុជា ក្នុងនោះមាន**ស្ត្រី១៧នាក់** និង៤៤នាក់មកពីគណបក្សសង្គ្រោះជាតិ ក្នុងនោះមាន**ស្ត្រី៣នាក់**)ក្នុងចំណោមតំណាងរាស្ត្រ១២៣នាក់ បានចុះមូលដ្ឋានសរុបចំនួន**១៦៦៥លើក** (គណបក្សប្រជាជនកម្ពុជាចំនួន ៥៦៤លើក ស្មើនឹង ៣៣,៨៧% និងគណបក្សសង្គ្រោះជាតិចំនួន ១១០១លើក ស្មើនឹង ៦១,១៣%) ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ មានការ**កើនឡើង**ចំនួន **៥៥៨លើក** ពី **១១០៧លើក** ឆ្នាំ២០១៥ មកដល់ **១៦៦៥លើក** ឆ្នាំ២០១៦ ។

គ្រប់សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គឺបានធ្វើឡើងក្នុងគោលបំណងសំខាន់ៗចំនួន**៥** រួមមាន *(១) ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានា (២)ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស (៣)ការចុះអមដំណើរថ្នាក់ដឹកនាំ (៤)ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការស៊ីវិល និង(៥)ការចុះជួយអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។*

## ១. ១. ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី

**<u>តារាងទី២</u> ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី**

| គោលបំណងនៃការចុះមូលដ្ឋានទាំង ៣៣៩លើករបស់អ្នកតំណាងរាស្ត្រស្ត្រី ចំនួន២០នាក់ | គណបក្សនយោបាយ | | សរុប |
|---|---|---|---|
| | ១៧ នាក់ | ៣ នាក់ | ២០ នាក់ |
| សកម្មភាពទាំង១៦៦៥លើករបស់អ្នកតំណាងរាស្ត្រ ផ្តោតទៅលើចំណុចមួយចំនួនដូចជា៖<br>✦ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ភោធសមិទ្ធិផលនានា | | | ២២១ លើក ៦៥,១៩% |
| ✦ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | | | ៧១ លើក ២០,៩៤% |
| ✦ការចុះអមដំណើរជាក្រុម ឬ អមដំណើរថ្នាក់ដឹកនាំ | | | ២៩ លើក ៨,៥៥% |
| ✦ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល | | | ៥ លើក ១,៤៧% |
| ✦ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ | | | ១៣ លើក ៣,៨៣% |
| **សរុបគោលបំណងតាមគណបក្ស** | ២២០ លើក ៦៤,៩០% | ១១៩ លើក ៣៥,១០% | ៣៣៩ លើក (១០០%) |

ក្នុងរយៈពេលនេះ អ្នកតំណាងរាស្ត្រស្ត្រីទាំង២០នាក់នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភាបានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន **៣៣៩លើក** ក្នុងនោះ *ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសម្ភោធសមិទ្ធិផលនានាមានចំនួន ២២១លើក ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សចំនួន៧១លើក ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន២៩លើក និងការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិលចំនួន៥លើក ព្រមទាំងការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា មាន១៣លើក* ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ចំនួនសកម្មភាពនេះ បាន**កើនឡើង**ចំនួន **៨៩លើក** ពី **២៥០លើក** ឆ្នាំ២០១៥ ទៅ **៣៣៩លើក** ឆ្នាំ២០១៦ ។

បើប្រៀបធៀប ពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការ**ខុសគ្នាឆ្ងាយ**រវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ភោធសមិទ្ធិផលនានាដែលមានចំនួន**២២១លើក** **(៦៥,១៩%)** ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជា*

*ពលរដ្ឋមានចំនួនតែ **១៣លើក** (៣,៨៣%)ប៉ុណ្ណោះ។* តួលេខនេះ នៅតែបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានានៅតែជាសកម្មភាពអាទិភាព និងសកម្មដដែល ដោយមានការ**កើនឡើង**ចំនួន**២៤លើក** ពី ១៩៧លើកឆ្នាំ២០១៥ ទៅ ២២១លើកឆ្នាំ២០១៦ ខណៈដែលនៅតែមានភាពមិនសូវសកម្មក្នុងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ បើទោះបីមានការ**កើនឡើងតិចតួច**ក៏ដោយ ពី ៧លើកឆ្នាំ២០១៥ ទៅ ១៣លើកឆ្នាំ២០១៦ ។*

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានក្នុងឆ្នាំ២០១៦ តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន **ច្រើនជាង** តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។ ជាក់ស្តែង តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចំនួន១៧នាក់ បានខិតខំធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួន**២២០លើក** គឺមានការ**កើនឡើងស្ទើរតែបីដង** បើធៀបនឹងឆ្នាំ២០១៥មានចំនួន១២នាក់បានធ្វើសកម្មភាពនៅមូលដ្ឋានចំនួនតែ៨៥លើកប៉ុណ្ណោះ ។ ចំណែកឯ តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិចំនួន៣នាក់ ក៏បានខិតខំធ្វើសកម្មភាពនៅមូលដ្ឋានដែរចំនួន **១១៩លើក**ក្នុងឆ្នាំ២០១៦ ប៉ុន្តែមានការ**ថយចុះ**បើធៀបនឹងឆ្នាំ២០១៥ មានចំនួន៥នាក់ បាន១៦៥លើកឯណោះ។

ទោះបីជាយ៉ាងណាក៏ដោយ បើគិតជាមធ្យមភាគនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រីម្នាក់ៗ រកឃើញថា *អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ **គឺមានភាពសកម្មជាង** អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា* ។ ជាក់ស្តែង អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិក្នុង១នាក់ បានចុះមូលដ្ឋានប្រមាណ**៤០លើក** (៣នាក់ ចំនួន១១៩លើក) រីឯ អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាក្នុង១នាក់ បានចុះមូលដ្ឋានប្រមាណតែ **១៣លើក** (១៧នាក់ ចំនួន២២០លើក)ប៉ុណ្ណោះ ។

<u>តារាងទី៣</u> ៖ ចំនួនតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្រប្រុសដែលបានចុះបេសកកម្មគិតជាភាគរយ

| តំណាងរាស្ត្របានចុះបេសកកម្ម៩៨នាក់ | | | |
|---|---|---|---|
| ស្ត្រី | % | ប្រុស | % |
| ២០នាក់ | ៨៣,៣៣% | ៧៨នាក់ | ៧៨,៧៩% |

*ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម **ច្រើនជាង**ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រប្រុសដែលបានចុះបេសកកម្ម* គឺ **៨៣,៣៣%** ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី២០នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៤នាក់ ច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្រប្រុសចំនួន **៧៨,៧៩%** ស្មើនឹង៧៨នាក់ក្នុងចំណោមសមាជិកសភាប្រុស៩៩នាក់ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម **បានកើនឡើង** ពី៧០,៨៣%ឆ្នាំ២០១៥ ទៅ

៨៣,៣៣%ឆ្នាំ២០១៦ ខណៈដែលភាគរយអ្នកតំណាងរាស្ត្រប្រុសចុះបេសកកម្មក៏មានការ**កើនឡើងដែរ** គឺពី ៧៧,៧៧% ឆ្នាំ២០១៥ ទៅ ៧៨,៧៩%ឆ្នាំ២០១៦ ។

<u>តារាងទី៤</u> ៖ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្រប្រុសនៃគណបក្សនីមួយៗ

| ឈ្មោះគណបក្ស | តំណាងរាស្ត្របានចុះបេសកកម្មធៀបនឹងចំនួនអាសនៈនៅក្នុងបក្សតាមភេទ | | | |
|---|---|---|---|---|
| **ប្រជាជនកម្ពុជា** | **តំណាងរាស្ត្រចុះបេសកកម្ម ៥៤នាក់(៧៩,៤១%) នៃ៦៨កៅអី** | | | |
| | ស្ត្រី | %នៃសមាជិកសភាស្ត្រី | បុរស | %នៃសមាជិកសភាបុរស |
| | ១៧នាក់ | ១០០% នៃ១៧កៅអី | ៣៧នាក់ | ៧២,៥៥% នៃ៥១កៅអី |
| **សង្គ្រោះជាតិ** | **តំណាងរាស្ត្រចុះបេសកកម្ម ៤៤នាក់(៨០%) នៃ៥៥កៅអី** | | | |
| | ស្ត្រី | %នៃសមាជិកសភាស្ត្រី | បុរស | %នៃសមាជិកសភាបុរស |
| | ៣នាក់ | ៤២,៨៦% នៃ៧កៅអី | ៤១នាក់ | ៨៥,៤២% នៃ៤៨កៅអី |

ដោយធ្វើការប្រៀបធៀបនៅក្នុងគណបក្ស របាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយរបស់ខុមហ្វ្រែលរកឃើញថា ភាគរយអ្នកតំណាងរាស្ត្រស្ត្រី**មកពីគណបក្សប្រជាជនកម្ពុជា** បានចុះបេសកកម្ម **១០០%** (១៧នាក់ក្នុងចំណោម ១៧នាក់) **ច្រើនជាង**ភាគរយអ្នកតំណាងរាស្ត្រប្រុសនៃគណបក្សរបស់ខ្លួនដែលមានចំនួនតែ**៧២,៥៥%** (៣៧នាក់ក្នុងចំណោម៥១នាក់) ប៉ុណ្ណោះ ។ បន្ថែមលើនេះទៀត បើប្រៀបធៀបនឹងឆ្នាំ២០១៥ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋានមានការ **កើនឡើងដល់ចំណុចកំពូល** គឺពី ៧០,៥៩% ឆ្នាំ២០១៥ ទៅដល់ ១០០% ឆ្នាំ២០១៦ ។ រីឯភាគរយអ្នកតំណាងរាស្ត្រប្រុសក៏មានការ**កើនឡើងដែរ** ពី ៥៨,៨២% ឆ្នាំ២០១៥ ទៅ ៧២,៥៥%ឆ្នាំ២០១៦ ។

ដោយឡែក ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ **តិចជាង** ភាគរយរបស់អ្នកតំណាងរាស្ត្រប្រុសនៃគណបក្សរបស់ខ្លួនដែលបានចុះបេសកកម្ម គឺភាគរយស្ត្រីស្មើនឹង **៤២,៨៦%** (៣នាក់ ក្នុងចំណោម៧នាក់) និងភាគរយបុរសមានចំនួន **៨៥,៤២%** (៤១នាក់ក្នុងចំណោម៤៨នាក់) ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន **បន្តថយចុះខ្លាំង** ពី ៨៥,៧១%ឆ្នាំ២០១៤ មកត្រឹម ៧១,៤៣%ឆ្នាំ២០១៥ រហូតមកត្រឹម៤២,៨៦%ឆ្នាំ២០១៦ ខណៈដែលភាគរយអ្នកតំណាងរាស្ត្រប្រុសក៏មានការ**ថយចុះ**ដែរ ពី៩៧,៩២% ឆ្នាំ២០១៥ មកត្រឹម ៨៥,៤២% ឆ្នាំ២០១៦ ។

តារាងទី៥ ៖ តំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មច្រើនជាងគេ

| ល.រ | ឈ្មោះតំណាងរាស្ត្រស្ត្រី | ឈ្មោះគណបក្ស | រូបសញ្ញា | ចំនួនសរុបចុះបេសកកម្ម |
|---|---|---|---|---|
| ១ | កែ សុវណ្ណរតន៍ | សង្គ្រោះជាតិ | | ១១២ លើក |
| ២ | នួម សុភ័ណ | ប្រជាជនកម្ពុជា | | ៥៩ លើក |
| ៣ | កែ ច័ន្ទមុនី | ប្រជាជនកម្ពុជា | | ៤៦ លើក |
| ៤ | ឡោក ខេង | ប្រជាជនកម្ពុជា | | ៣៤ លើក |
| ៥ | ម៉ែន សំអន | ប្រជាជនកម្ពុជា | | ១៥ លើក |
| ៦ | ត្រឹង ថារី | ប្រជាជនកម្ពុជា | | ១៥ លើក |

តារាងទី៥ បង្ហាញថា តំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្ម**ច្រើនជាងគេបំផុត** នៅក្នុងឆ្នាំសង្កេតទី៣ នេះ គឺ **លោកជំទាវ កែ សុវណ្ណរតន៍** តំណាងរាស្ត្រមណ្ឌលសៀមរាបមកពីគណបក្សសង្គ្រោះជាតិមានចំនួន **១១២លើក** គឺមាន**ការកើនឡើងរៀងរាល់ឆ្នាំ** បើធៀបនឹងឆ្នាំ២០១៥មានចំនួន **៨៨លើក** និងឆ្នាំ២០១៤មានចំនួន**៤០លើក** ។ អ្នកដែល**ច្រើនបន្ទាប់**មានចំនួន៣នាក់ដែលមកពីគណបក្សប្រជាជនកម្ពុជា ដូចជា **លោកជំទាវ នួម សុភ័ណ** មានចំនួន **៥៩លើក** គឺ**កើនឡើងស្ទើរតែ១០០%** បើធៀបនឹងឆ្នាំ២០១៥មានចំនួនតែ ២លើកប៉ុណ្ណោះ ។ រីឯ**លោកជំទាវ កែ ច័ន្ទមុនី** មានចំនួន**៤៦លើក** គឺ**កើនឡើង៥ដង** បើធៀបនឹងឆ្នាំ២០១៥មានចំនួន៩លើក និង**លោកជំទាវ ឡោក ខេង** មានចំនួន**៣៤លើក** គឺ**កើនឡើងស្ទើរតែ២ដង** បើធៀបនឹងឆ្នាំ២០១៥មានចំនួន១៩លើក ។

*សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី និងបុរសខាងលើ គឺមិនមានបង្ហាញអំពីលទ្ធផលជាក់ស្តែងដែលបានដោះស្រាយ ឬការធ្វើអន្តរាគមន៍របស់ពួកគាត់នៅតាមមណ្ឌលនីមួយៗឡើយ ។ អ្នកសង្កេតការណ៍ខុមហ្វ្រែលព្យាយាមទំនាក់ទំនងរកព័ត៌មានទាំងនេះ ប៉ុន្តែនៅតែមិនមានការឆ្លើយតបអំពីរឿងនេះ។*

## ២. សភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី (Women Parliamentarian Caucus )សមាជិករដ្ឋសភា

ក្នុងចំណោមសកម្មភាពជាច្រើន ខុមហ្វ្រែលបានដកស្រង់ចំណុចសំខាន់មួយចំនួនក្នុងរបាយការណ៍សង្ខេបជាចំណុចៗសកម្មភាពរបស់ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី(កសកនស)ក្នុងឆ្នាំ២០១៦ មានដូចខាងក្រោម[2] ៖

- នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ លោកជំទាវ **តែ ច័ន្ទមនី** លោកជំទាវ **ហ៊ូ ណួន** និងជំនួយការកសកនស បានចូលរួមសិក្ខាសាលាស្តាប់បទបង្ហាញលទ្ធផលនៃកិច្ចស្រាវជ្រាវ «បញ្ហាប្រឈមរបស់ស្ត្រីថ្នាក់ដឹកនាំក្រោមជាតិ ក្នុង

[2] របាយការណ៍សង្ខេបជាចំណុចៗសកម្មភាពរបស់ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី ប្រចាំឆ្នាំ២០១៦ (ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦)

ការទាញយកថវិកាមកប្រើប្រាស់សម្រាប់ស្ត្រី និងកុមារ» ដែលឧបត្ថម្ភដោយអង្គការ Oxfam at Imperial Garden រាជធានីភ្នំពេញ ។

- នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ លោកជំទាវ **ស៊ុន សាភឿន** បានចូលរួមទិវានារីអន្តរជាតិ ៨ មីនា លើកទី១០៥ ក្រោមប្រធានបទ «ខ្ញុំបោះឆ្នោតឲ្យស្ត្រី ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ ដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅភោជនីយដ្ឋានទន្លេរបាសាក់» ។

- នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៦ លោកជំទាវ យូន សុដារី អញ្ជើញចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយបងប្អូនក្នុងជួរគណៈកម្មាធិការបក្សឃុំ ក្រុមការងារយុវជន យុវនារីនៅឃុំសណ្ដារ ស្រុកលើកដែកខេត្តកណ្ដាល ។

- នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ លោកជំទាវ **យូន សុដារី** អញ្ជើញចូលរួមសិក្ខាសាលាស្ដីពី «ការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្ដីព្រាងច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ នៅរដ្ឋសភា ។

- នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ លោកជំទាវ **យូន សុដារី** បានអនុញ្ញាតឲ្យលោក Tomasz Miklaszewski ទីប្រឹក្សាស្ថានទូតប៉ូឡូញ ដែលមាននិវេសនដ្ឋាននៅទីក្រុងបាងកក បានជួបពិភាក្សាការងារស្ដីអំពី លទ្ធភាពកិច្ចសហប្រតិបត្តិការរវាងក្រុមសមាជិការដ្ឋសភានៃប្រទេសទាំងពីរ ។

- នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ លោកជំទាវ **យូន សុដារី** បានដឹកនាំក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រីចូលរួមក្នុងកិច្ចសំណេះសំណាលទាក់ទងនឹងច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និងយន្តការផ្សេងៗដែលមានស្រាប់ ដើម្បីទប់ស្កាត់ និងដោះស្រាយអំពើហឹង្សាលើយេនឌ័រ ជាពិសេសកើតនៅកន្លែងធ្វើការ ជាមួយលោក **អ៊ីល ប្រោន** នាយកកម្មវិធីផ្នែកបច្ចេកទេស ទទួលបន្ទុកកម្មវិធីច្បាប់ និងជាមេធាវីផ្នែកនីតិការងាររបស់មជ្ឈមណ្ឌលសាមគ្គីភាពអាមេរិកាំង ។

- នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦ លោកជំទាវ **យូន សុដារី** បាននាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តឯកទេសព្យាបាលជំងឺភ្នែកមួយក្រុម មានឈ្មោះថា «ក្រុមគ្រូពេទ្យសហគមន៍គាំពារភ្នែកកម្ពុជាអន្តរជាតិ» មកពីអូស្ត្រាលីទៅពិនិត្យ និងព្យាបាលជំងឺភ្នែកជូនប្រជាពលរដ្ឋដល់មូលដ្ឋានស្រុកលើកដែកចំនួន ៥៧៥នាក់ ។ ហើយនៅថ្ងៃទី២២ និងថ្ងៃ២៣ ប្រជាពលរដ្ឋចំនួន ១៥៣រូបនឹងត្រូវទៅវះកាត់ភ្នែកនៅមន្ទីរពេទ្យកម្ពុជា-សូវៀត ។

- ពីថ្ងៃទី ២៥-២៨ ខែសីហា ឆ្នាំ២០១៦ លោកជំទាវ **យូន សុដារី** អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិលើកទី២នៃសភាតំបន់អាស៊ី នៅសណ្ឋាគារស្វហ្វីតែល ភូគីត្រា ។

- ពីថ្ងៃទី ២៩ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៦ លោកជំទាវ **និន សាផុន** បានដឹកនាំគណៈប្រតិភូគណៈកម្មាធិការ WAIPA ចូលរួមកិច្ចប្រជុំគណៈកម្មាធិការWAIPAនៃមហាសន្និបាតអាយប៉ាលើកទី៣៧ នៅទីក្រុងណៃពិដោ ប្រទេសភូមា ។

- នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ លោកជំទាវ **យូន សុដារី** ធ្វើបទបង្ហាញក្នុងវេទិកាស្ត្រី ស្ដីពី «គោលនយោបាយគណបក្សប្រជាជនកម្ពុជាគាំទ្រការបង្កើនចំនួនស្ត្រីក្នុងវិស័យនយោបាយ នៅព្រឹទ្ធសភា ។

- នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ លោកជំទាវ **យូន សុដារី** បានដឹកនាំអង្គប្រជុំសមាជិកសភាជាស្ត្រីAPA ដើម្បីត្រៀមចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការសមាជិកសភាជាស្ត្រីនៃមហាសន្និបាតAPA លើកទី៩ ។

- ពីថ្ងៃទី២៧ ខែវិច្ឆិកា ដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ លោកជំទាវ យូន សុដារីបានចូលរួមកិច្ចប្រជុំ និងដឹកនាំ កិច្ចប្រជុំគណៈកម្មាធិការសមាជិកសភាស្ត្រី សភាតំបន់អាស៊ីនៃមហាសន្និបាតAPA លើកទី៩ នៅខេត្តសៀមរាប ។

- ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ លោកជំទាវ **យូន សុដារី** បានអនុញ្ញាតឲ្យលោក Tomasz Miklaszewski ទីប្រឹក្សាផ្នែកនយោបាយ សេដ្ឋកិច្ច និងលោក **Ambroziak Robert** លេខាទូតទី១ នៃស្ថានទូតប៉ូឡូញប្រចាំនៅទីក្រុងបាងកកចូល ជួបពិភាក្សាការងារស្ដីពីការផ្លាស់ប្តូរបទពិសោធរវាង Women Caucus កម្ពុជា និង Women Caucus ប៉ូឡូញ ។

*សកម្មភាពខាងលើនេះ ភាគច្រើនមិនបានបង្ហាញអំពីលទ្ធផលនៃកិច្ចប្រជុំ ឬក៏សេចក្ដីសម្រេចណាមួយទាក់ទងនឹងការចូលរួមដោះស្រាយបញ្ហាស្ត្រី និងកុមាររបស់កសកនសឡើយ និងពុំបានបង្ហាញឲ្យឃើញអំពីសាមគ្គីភាពនៅក្នុងក្រុមស្ត្រី និងអំពីការប្រឈមអ្វីខ្លះក្នុងពេលប្រតិបត្តិការការងារដែរ ។*

## III. ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ

សំណួរសួរថា ***តើម្ចាស់ឆ្នោតពេញចិត្តការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួលបានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានក្នុងកម្រិតណា?***

យោងតាមរបាយការណ៍ឃ្លាំមើលរដ្ឋាភិបាល អាណត្តិទី៥របស់ខុមហ្វ្រែល ម្ចាស់ឆ្នោតចំនួន១៨រាជធានី ខេត្តបានផ្ដល់ពិន្ទុទៅលើការបំពេញកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំទី៣ ក្នុងឆ្នាំ២០១៦ ជាលទ្ធផលបង្ហាញថា « ម្ចាស់ឆ្នោត *ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង*ចំនួនចន្លោះពី **៨០% ទៅ ១០០%**ដែលជាភាគរយខ្ពស់បំផុត ។ ភាគរយខ្ពស់បន្ទាប់ គឺ ម្ចាស់ឆ្នោត***ពេញចិត្តច្រើន*** ចំនួនចន្លោះពី **៦១% ទៅ ៨០%** ។ ភាគរយមធ្យម គឺ ម្ចាស់ឆ្នោត*ពេញចិត្ត*

*មធ្យម ឬពេញចិត្តពាក់កណ្តាល* ចំនួនចន្លោះពី **៤១% ទៅ ៦០%** ។ រីឯ ភាគរយទាបជាងគេ គឺ ***ម្ចាស់ឆ្នោតពេញចិត្តខ្លះ*** ចំនួនចន្លោះពី **២១% ទៅ ៤០%** និង***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច***មានចំនួនចន្លោះពី **0% ទៅ ២០%** ប៉ុណ្ណោះ។

តួលេខខាងលើបញ្ជាក់ឲ្យឃើញថា ឆ្នាំ២០១៦គឺជាឆ្នាំគួរឲ្យភ្ញាក់ផ្អើល ដែលម្ចាស់ឆ្នោតបានផ្តល់ពិន្ទុគាំទ្រខ្ពស់បំផុតទាក់ទងនឹងការបំពេញកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ ជាក់ស្តែង បើប្រៀបធៀបនឹងឆ្នាំ២០១៥ ម្ចាស់ឆ្នោតបានផ្តល់ភាគរយខ្ពស់បំផុតក្នុងការ**ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង**ដែលមានចំនួនចន្លោះពី ៨០% ទៅ ១០០%ឆ្នាំ២០១៦នេះ ដែលខុសគ្នាដាច់ស្រឡះពីឆ្នាំ២០១៥ដែលជាភាគរយទាបបំផុត គឺ ៨,១៤% គឺ**កើនឡើងខ្លាំងប្រមាណជាង ៨០%** ។ ចំណែកឯ ម្ចាស់ឆ្នោត***ពេញចិត្តច្រើន*** ក៏មានការ**កើនខ្លាំងដែរប្រមាណជាង ៦០%** ពី ៦១% ទៅ ៨០% ឆ្នាំ២០១៦ និង ១១,៣២% ឆ្នាំ២០១៥ ខណៈដែលម្ចាស់ឆ្នោត***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច***ក៏មានការ**ធ្លាក់ចុះ**ដែរ ពី ២៧,៦៣% ឆ្នាំ២០១៥ មកត្រឹម ចន្លោះពី 0% ទៅ ២0% ឆ្នាំ២០១៦ ។ តួលេខនេះបង្ហាញថា ការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងកុមារទទួលបានសិទ្ធិជាមូលដ្ឋានរបស់រាជរដ្ឋាភិបាលកម្ពុជាមានភាព**ប្រសើរជាងមុន** ដែលធ្វើឲ្យម្ចាស់ឆ្នោតចាប់ផ្តើមគាំទ្រ និងពេញចិត្ត ។

## IV. ស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦

មាត្រា១៦៧នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(ច.ប.ត.រ) បានបញ្ញត្តិឲ្យមានការរៀបចំបញ្ជីបោះឆ្នោតថ្មី សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ។

ក្នុងការរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦នេះ គឺប្រើប្រាស់**ប្រព័ន្ធចុះឈ្មោះតាមបែបទំនើប**ជាលើកដំបូងសម្រាប់ប្រទេសកម្ពុជា ដែលជាដំណើរការថ្មីមួយនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាបាននូវការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ឲ្យកាន់តែមានអព្យាក្រិតភាព សុច្ចរឹតភាព យុត្តិធម៌ និងតម្លាភាព ។

ការរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦នេះ បានតម្រូវឲ្យប្រជាពលរដ្ឋខ្មែរទាំងអស់ដែលគ្រប់អាយុបោះឆ្នោត ត្រូវទៅចុះឈ្មោះបោះឆ្នោតឡើងវិញ ។ ការចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមធ្វើនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេសក្នុងថ្ងៃតែមួយ ដែលបានកំណត់ដោយគ.ជ.ប ដែលមានរយៈពេល ៩១ (កៅសិបមួយ)ថ្ងៃ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការចុះឈ្មោះជារៀងរាល់ថ្ងៃពីថ្ងៃច័ន្ទ ដល់ ថ្ងៃអាទិត្យ ចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ១១:៣០ថ្ងៃត្រង់ និងពេលរសៀលចាប់ពីម៉ោង ២:០០ ដល់ម៉ោង ៥:៣០នាទីល្ងាច ។

ដើម្បីចង់ដឹង ថាតើការចុះឈ្មោះបោះឆ្នោតថ្មីនេះ *មានប្រសិទ្ធភាពកម្រិតណា? មានចំណុចខ្វះខាតអ្វីខ្លះដែលត្រូវកែលំអរ? ភាពងាយស្រួល និងការលំបាករបស់ប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត* ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួននៅទូទាំងប្រទេស ក្នុងនោះក៏បានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីនៅក្នុងឃុំ សង្កាត់ចំនួន១០ នៅក្នុងស្រុក ខណ្ឌចំនួន៦ និង៦ខេត្ត ក្រុង ដូចជា ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តតាកែវ និងខេត្តព្រះវិហារ **ក្នុងគោលបំណង** *សិក្សាអំពីការចូលរួមនយោបាយរបស់ស្ត្រីក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ និងផលប៉ះពាល់មកលើស្ត្រី* ។ ការដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីនេះមានលក្ខណៈពិសេសខុសពីការសង្កេតការណ៍ទូទៅ គឺអ្នកសង្កេតការណ៍ស្ត្រីទាំងអស់បាន*ប្រមូលទិន្នន័យបែបគុណភាពដោយផ្តោតសំខាន់លើករណីសិក្សា(Qualitative Collection)* ។ ព័ត៌មានសំខាន់៤ដែលត្រូវផ្តោតការយកចិត្តទុកដាក់មានដូចជា **(១)ព័ត៌មានក្នុងឃុំ សង្កាត់** ទាក់ទងនឹងចំនួនប្រជាពលរដ្ឋ ស្ថានភាព និងចំនួនគណបក្សនយោបាយដែលមានស្នាក់ការនៅក្នុងឃុំ សង្កាត់ ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មកពីគណបក្សណាខ្លះ? ។ **(២) ព័ត៌មានអំពីការចុះឈ្មោះបោះឆ្នោត**ទាក់ទងនឹងភាពលំបាក និងភាពងាយស្រួលរបស់អ្នកចុះឈ្មោះបោះឆ្នោតជាស្ត្រី មូលហេតុអ្វីស្ត្រីមិនបានចុះឈ្មោះបោះឆ្នោត? មូលហេតុអ្វីស្ត្រីបានចុះឈ្មោះបោះឆ្នោត? និងការទទួលបានព័ត៌មានអំពីការចុះឈ្មោះបោះឆ្នោត ។ **(៣) ព័ត៌មានអំពីស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត** ទាក់ទងនឹងសមាសភាពរបស់ក្រុមការងារចុះឈ្មោះបោះឆ្នោត តើពួកគេត្រូវធ្វើយ៉ាងដូចម្តេចដើម្បីក្លាយជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត? ប្រវត្តិរបស់ស្ត្រីជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត? ហេតុអ្វីបានជាចង់ក្លាយជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត? ។ **(៤) ព័ត៌មានអំពីអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ** ទាក់ទងនឹងការរារាំងដល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយមិនឲ្យតាមសង្កេតដំណើរការចុះឈ្មោះបោះឆ្នោត និងភាពងាយស្រួលរបស់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ ។

ដើម្បីឲ្យកិច្ចការនេះមានប្រសិទ្ធភាព ខុមហ្វ្រែលបានជ្រើសរើសអ្នកសង្កេតការណ៍ជាស្ត្រីចំនួន១០នាក់ (១នាក់ក្នុង១ឃុំ សង្កាត់(ជាអ្នករស់នៅក្នុងឃុំ សង្កាត់ដែលខ្លួនត្រូវសង្កេតការណ៍ គឺជាឃុំ សង្កាត់ដែលមានសមាសភាពស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ត្រីដែលជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត)។ ស្ត្រីអ្នកសង្កេតការណ៍ទាំងនោះបានទទួលការបណ្តុះបណ្តាលពីទីស្នាក់ការកណ្តាលខុមហ្វ្រែលភ្នំពេញ *អំពីរបៀបនៃការសង្កេតការណ៍ប្រមូលទិន្នន័យបែបគុណភាព ទាក់ទងនឹងការចូលរួមរបស់ស្ត្រី និងផលប៉ះពាល់មកលើស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតដោយផ្តោតសំខាន់ទៅលើករណីសិក្សា និងអំពីរបៀបបំពេញរបាយការណ៍ដោយត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត* ផងដែរ ។

ស្ត្រីអ្នកសង្កេតការណ៍ទាំងអស់បានអនុវត្តតាមវិធីសាស្ត្រដូចជា៖ *ការសង្កេតការណ៍ដោយផ្ទាល់នៅកន្លែងចុះឈ្មោះបោះឆ្នោត ការសម្ភាសន៍តាមបែបសំណេះសំណាល(Semi-Interview)ជាមួយអ្នកចុះឈ្មោះបោះឆ្នោត និងអ្នកមិនបានចុះឈ្មោះបោះឆ្នោតជាស្ត្រី ព្រមទាំងស្ត្រីដែលជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត និងសម្ភាសន៍ផ្ទាល់(Interview)ជាមួយ*

*ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ត្រីពាក់ព័ន្ធផ្សេងទៀត* ។ ជាក់ស្តែង អ្នកសង្កេតការណ៍ស្ត្រីបានធ្វើសកម្មភាពជាមួយនឹងក្រុមគោលដៅទាំងនេះ ដូចជា៖ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ២៦នាក់ ស្មើនឹង ៣២,២៣%នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ស្រី-ប្រុសសរុប ៨៦នាក់ ។ ស្ត្រីជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត (កចប)ចំនួន ១៩នាក់ ស្មើនឹង ៣៨%នៃចំនួនមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោតសរុប ៥០នាក់ ។ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ (ប្រចាំការ)ចំនួន ១៤នាក់ ស្មើនឹង ៤៦,៦៦%នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ស្រី-ប្រុសប្រចាំការសរុប ៣០នាក់ ។ ស្ត្រីភ្នាក់ងារគណបក្សនយោបាយចំនួន ៨នាក់ ស្មើនឹង ១២,៥០%នៃចំនួនភ្នាក់ងារគណបក្សនយោបាយសរុប ៦៤នាក់ ។ ស្ត្រីអ្នកសង្កេតការណ៍ចំនួន ១២នាក់ ស្មើនឹង ៩២,៣០%នៃចំនួនសរុប ១៣នាក់ ។ ស្ត្រីបានចុះឈ្មោះបោះឆ្នោតចំនួន ៥៦នាក់ និងស្ត្រីមិនបានចុះឈ្មោះបោះឆ្នោតចំនួន ១៩នាក់ ។

## ១. ព័ត៌មាន និងស្ថានភាពឃុំ សង្កាត់

### ១. ១. អំពីសន្តិសុខ សុវត្ថិភាព និងការភ័យខ្លាចនៅក្នុងឃុំ សង្កាត់

ទាក់ទិននឹងសន្តិសុខ សុវត្ថិភាព និងការភ័យខ្លាចនៅក្នុងឃុំ សង្កាត់ទាំង១០ អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលបានជួបសម្ភាសន៍ជាមួយនឹងក្រុមគោលដៅជាស្ត្រីមួយចំនួនដូចជា៖ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋស្ត្រី និងការសង្កេតដោយអ្នកសង្កេតការណ៍ខ្លួនឯងបានបង្ហាញថា៖ សុវត្ថិភាពក្នុងភូមិ ឃុំកន្លងមក ធ្លាប់មានបញ្ហាអសន្តិសុខខ្លះៗដែរ ដូចជា ចោរលួច ឆក់ និងក្មេងទំនើង ប៉ុន្តែ បច្ចុប្បន្នមានសុវត្ថិភាពល្អនៅក្នុងភូមិ ឃុំហើយ ។ ភូមិ ឃុំខ្លះទៀតថាកាលពីមុនក៏មិនសូវមានសុវត្ថិភាពដែរ... ប្រជាពលរដ្ឋហាក់មានការភ័យខ្លាច តែក្នុងរយៈពេលនៃការចុះឈ្មោះបោះឆ្នោតនេះ មានការបង្កើនការយកចិត្តទុកដាក់ខាងផ្នែកសន្តិសុខទ្វេរដង ។ អញ្ចឹងហើយមិនមានអ្វីជាបញ្ហាទេ មានសុវត្ថិភាពល្អ មានប៉ូលីស និងសមត្ថកិច្ចការពារត្រឹមត្រូវ រាល់ពេលមានបញ្ហាមានកិច្ចអន្តរាគមន៍ទាន់ពេលភ្លាមៗ ។ ចំណែកឯក្រុមប្រឹក្សាឃុំ សង្កាត់ក៏មានការយកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋដែរ ។ សរុបមក គឺថា ប្រជាពលរដ្ឋមិនមានអារម្មណ៍ភ័យខ្លាចទេ ដោយសារមានការយកចិត្តទុកដាក់ខាងផ្នែកសុវត្ថិភាព និងសន្តិសុខ។

ចំណែកឯការចុះឈ្មោះបោះឆ្នោតលើកនេះ មានការងាយស្រួល មានសុវត្ថិភាពល្អ មានប៉ូលីស និងសមត្ថកិច្ចការពារត្រឹមត្រូវ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏មានការយកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋដែរ រាល់ពេលមានបញ្ហាមានកិច្ចអន្តរាគមន៍ទាន់ពេលភ្លាមៗ ។

### ១. ២. ស្ថានភាពគណបក្សនយោបាយ

ទាក់ទិននឹងស្ថានភាពគណបក្សនយោបាយ អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលបានរកឃើញថា ជាទូទៅមានវត្តមានគណបក្សនយោបាយចន្លោះពី ២ ទៅ ៦គណបក្សនៅក្នុងឃុំ សង្កាត់ទាំង១០នេះដូចជា ៖ គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ គណបក្សសម រង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសម្ព័ន្ធដើម្បីប្រជា

ធិបតេយ្យ គណបក្សខ្មែរជួយខ្មែរ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ។ល។ ប៉ុន្តែ គណបក្សដែលមានទីស្នាក់ការនៅក្នុងឃុំ សង្កាត់ មានតែ ២ ទៅ ៣ គណបក្សប៉ុណ្ណោះ ។ ជាក់ស្តែង មានតែគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។

ចំណែកឯសកម្មភាពទម្លាក់ស្លាកគណបក្សនយោបាយនៅក្នុងឃុំ សង្កាត់ គឺមិនមានព័ត៌មានទាក់ទិននឹងការទម្លាក់ស្លាកនេះទេ ។

## ២. ព័ត៌មានស្តីពីការចុះឈ្មោះបោះឆ្នោត

### ២. ១. ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោតប្រចាំឃុំ សង្កាត់ (កចប)

| មន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត (កចប) | | |
|---|---|---|
| ចំនួន ស្ត្រី | %ស្ត្រី | ចំនួនសរុប (ស្រី - ប្រុស) |
| **១៩នាក់** | **៣៨%** | **៥០នាក់** |

ក្នុងចំណោម១០ ឃុំ សង្កាត់ ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត(កចប)មានចំនួនតែ ១៩នាក់ ស្មើនឹង ៣៨% នៃចំនួនមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោតសរុប ៥០នាក់ ក្នុងនោះ **៣នាក់***មានតួនាទីជាប្រធានកចប* **៤នាក់***ជាអនុប្រធាន (ស្មៀន)*នៃក្រុមចុះឈ្មោះបោះឆ្នោត **៨នាក់***ជាការីកុំព្យូទ័រ* និង**៤នាក់ទៀត***ជាជំនួយការប្រធានកចប* ។ ហេតុផលរបស់ស្ត្រីកចបទាំងនោះបានចូលរួមធ្វើកិច្ចការចុះឈ្មោះបោះឆ្នោត បង្ហាញថា៖ ស្ត្រីកចប ដែលអាចទទួលតួនាទីជាមន្ត្រីកចប ដោយសារគាត់ជានិស្សិត ធ្លាប់ជាគ្រូបង្រៀន ជាមន្ត្រីរាជការ និងធ្លាប់ជាសមាជិកគណៈកម្មការរៀបចំការចុះឈ្មោះបោះឆ្នោត ព្រមទាំងមានសមត្ថភាពក្នុងការវាយកុំព្យូទ័រផងដែរ ។ ជាពិសេស ស្ត្រីទាំងនោះចង់មានបទពិសោធក្នុងកិច្ចការបោះឆ្នោត និងចង់ជួយកិច្ចការសង្គម ។

បើទោះបីតួលេខស្ត្រីមានភាពប្រសើរបន្តិចក៏ដោយ ប៉ុន្តែស្ត្រីភាគច្រើនបានទទួលតួនាទីត្រឹមតែជាការីកុំព្យូទ័រ និងជំនួយការប្រធានប៉ុណ្ណោះ ។

## ២. ២. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

### ក. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ

| ក្រុមប្រឹក្សាឃុំ សង្កាត់ (ប្រចាំការ) | | |
|---|---|---|
| ចំនួនស្ត្រី | % ស្ត្រី | ចំនួនសរុប (ស្រី - ប្រុស) |
| ១៤នាក់ | ៤៦,៦៦% | ៣០នាក់ |

ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់បានដើរតួនាទីសំខាន់ក្នុងការបញ្ជាក់ឯកសារមួយចំនួនដល់ម្ចាស់ឆ្នោតសម្រាប់បម្រើការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ដែលតម្រូវឲ្យមានសមាជិក ឬប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួនត្រូវតែនៅប្រចាំការនៅទីស្នាក់ការឃុំ សង្កាត់របស់ខ្លួនជាទៀងទាត់។ ក្នុងចំណោម ១០ ឃុំ សង្កាត់ដែលអ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលបានសង្កេត បានរកឃើញថា មានស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការចំនួន ១៤នាក់ ស្មើនឹង ៤៦,៦៦%នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការសរុប ៣០នាក់ ។ ស្ត្រីក្រុមប្រឹក្សាប្រចាំការទាំងនោះបានប្រាប់ពីស្ថានភាពនៃដំណើរការនៃការចុះឈ្មោះបោះឆ្នោតថា *«ពួកគាត់ជាអ្នកជួយប្រាប់ប្រជាពលរដ្ឋដែលមិនមានឯកសារគ្រប់ឲ្យមកបញ្ជាក់ឯកសារសម្រាប់ចុះឈ្មោះបោះឆ្នោត និងបានឃើញពីការលំបាកនៃក្រុមចុះឈ្មោះបោះឆ្នោតនៅពេលមានប្រជាពលរដ្ឋមកចុះឈ្មោះច្រើន»* ។

### ខ. ស្ត្រីក្រុមប្រឹក្សាឃុំសង្កាត់មិនប្រចាំការ

ចំណែកឯ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនប្រចាំការវិញ ក៏បានបង្ហាញពីមតិយោបល់របស់ខ្លួនដែរថា៖ *« ចំពោះស្ថានភាពក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត ឃើញមានការយកចិត្តទុកដាក់ពីប្រជាពលរដ្ឋដោយមកចុះឈ្មោះកើនឡើង ដំណើរការចុះឈ្មោះបោះឆ្នោតមានភាពត្រឹមត្រូវ និងមិនមានបញ្ហាអ្វីគួរឲ្យកត់សម្គាល់ឡើយ ។ ប៉ុន្តែភាគច្រើនអ្នកធ្វើការរោងចក្របាក់មិនសូវយកចិត្តទុកដាក់ ដោយសារតែមានការបាត់អត្តសញ្ញាណប័ណ្ណ និងផ្លាស់ប្តូរលំនៅដ្ឋាន »*។

ទាំងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការក្តី មិនប្រចាំការក្តី បានសំណូមពរប្រហាក់ប្រហែលគ្នាថា៖ *«សូមបន្ថែមចំនួនមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោតសម្រាប់ការចុះឈ្មោះបោះឆ្នោតលើកក្រោយៗទៀត ដើម្បីកុំឲ្យយឺតយ៉ាវ អ្នកមកចុះឈ្មោះរង់ចាំយូរ និងសូមមានការអនុញ្ញាតឲ្យកម្មករ កម្មការិនីរោងចក្រចំនួន៣ថ្ងៃយ៉ាងតិចបានទៅចុះឈ្មោះបោះឆ្នោតនៅលំនៅដ្ឋានរបស់ខ្លួន។ បន្ថែមលើនេះទៀត សូមឲ្យមានក្រុមចុះឈ្មោះបោះឆ្នោតចល័តតាមផ្ទះ ដើម្បីបង្ករការងាយស្រួល ទើបប្រជាពលរដ្ឋបានចុះឈ្មោះគ្រប់ៗគ្នា»* ។

## ២. ៣. អំពីការចុះឈ្មោះបោះឆ្នោត

### ក. ស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត

យោងតាមលទ្ធផលផ្លូវការនៃការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ចេញផ្សាយដោយគ.ជ.ប[3] ស្ត្រីបានចុះឈ្មោះបោះឆ្នោតច្រើនលើសជាងការចុះឈ្មោះបោះឆ្នោតលើកមុនៗ រហូតដល់ **៥៣,៥៣% ស្មើនឹង ៤ ២១០ ៩១៤នាក់** នៃអ្នកបានចុះឈ្មោះបោះឆ្នោតសរុប **៧ ៨៦៥ ០៣៣នាក់** ។ អ្នកសង្កេតការណ៍ស្ត្រីខុមប្រែហ្វលបានជួប**សម្ភាសន៍បែបសំណេះសំណាល**ជាមួយនឹងស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត ចំនួន ៥៦នាក់ ដោយទទួលបានហេតុផលមួយចំនួនៈ

| អំពីទិដ្ឋភាពរួមទាក់ទងនឹងដំណើរការចុះឈ្មោះបោះឆ្នោតក្នុងឃុំ-សង្កាត់ |
|---|
| ទីកន្លែងសំរាប់ការចុះឈ្មោះនៅតាមសាលារៀន ធំទូលាយ ស្ងប់ស្ងាត់ល្អ គ្មានការគំរាមកំហែង |
| មានការយកចិត្តទុកដាក់ណែនាំ ជួយសម្រួលពីមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត មានភាពសុក្រិត្យល្អ |
| ហាក់មានការលំបាក សំរាប់អ្នកគ្មានអត្តសញ្ញាណប័ណ្ណ |
| មានប៉ូលីសនៅចាំជួយអន្តរាគមន៍ នៅខាងក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត |
| មិនមានភាពរញ៉េរញ៉ៃទេ |

| អំពី«ភាពងាយស្រួល»នៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ-សង្កាត់ |
|---|
| មិនរង់ចាំយូរបើមានឯកសារគ្រប់គ្រាន់ តាមលំដាប់លេខរៀង |
| បើមានឯកសារគ្រប់គឺងាយស្រួលបំផុត រីឯអ្នកមិនមានឯកសារគ្រប់ គឺមានមន្ត្រីពាក់ព័ន្ធជួយសម្រួលដើម្បីឲ្យមានឯកសារគ្រប់គ្រាន់ ។ |

| អំពី«ការលំបាក»នៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ-សង្កាត់ |
|---|
| ការលំបាកមានសំរាប់តែអ្នកគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ និងបានផ្លាស់ទីលំនៅត្រូវការឯកសារបញ្ជាក់ ត្រូវការអត់ធ្មត់ ។ |

[3] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញផ្សាយជាសាធារណៈនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៧ អំពី «លទ្ធផលផ្លូវការនៃការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦»

| ល.រ | អំពី«នីតិវិធី/របៀប»នៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ-សង្កាត់ |
|---|---|
| | ទាក់ទិននឹងដំណើរការចុះឈ្មោះបោះឆ្នោត ស្ត្រីដែលបានចុះឈ្មោះបានឆ្លើយរបៀបសាមញ្ញៗ បង្ហាញពីដំណើរការនោះ៖ |
| ១ | ហុចអត្តសញ្ញាណប័ណ្ណឲ្យទៅប្រធានក្រុមចុះឈ្មោះបោះឆ្នោត |
| ២ | ហើយអង្គុយចាំបន្តិច គេហុចចុងសន្លឹកឲ្យ |
| ៣ | ហើយទៅអង្គុយកន្លែងថតរូប ផ្តិតមេដៃ |
| | **មានន័យថា៖** អ្នកចុះឈ្មោះបោះឆ្នោតប្រគល់ឯកសារបញ្ជាក់អត្តសញ្ញាណ ➡ ទៅឲ្យប្រធានផ្ទៀងផ្ទាត់ ➡ រួចហុចឲ្យអនុប្រធានដើម្បីបំពេញ ➡ អ្នកចុះឈ្មោះបោះឆ្នោតទទួលចុងសន្លឹក ➡ និងបន្តទៅថតរូប ផ្តិតមេដៃ |

| មូលហេតុដែលស្ត្រីទៅចុះឈ្មោះបោះឆ្នោត |
|---|
| - ដើម្បីជាតិ ស្រឡាញ់គណបក្ស ចង់ឲ្យគណបក្សដែលខ្លួនស្រឡាញ់បានឈ្នះ អភិវឌ្ឍន៍ក្នុងឃុំ សង្កាត់ និងដោយសារគិតថាជាតួនាទីរបស់ប្រជាពលរដ្ឋត្រូវតែបំពេញ។ |
| - កុំឲ្យបាត់សម្លេងឆ្នោត (ខ្លាចខាតសន្លឹកឆ្នោតមួយសន្លឹករបស់ខ្លួន) |
| - បំពេញកាតព្វកិច្ចជាពលរដ្ឋ |
| - ចង់ជ្រើសរើសតំណាងល្អ |

### ខ. ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត

ដោយផ្អែកទៅលើលទ្ធផលជាក់ស្តែង ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោតពិតជាពិបាករកមកធ្វើការសម្ភាសន៍ពីព្រោះឃុំ សង្កាត់ខ្លះស្ត្រីបានទៅចុះឈ្មោះស្ទើរតែទាំងស្រុង ។ ទោះជាយ៉ាងនេះក្តី អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលក៏បានខិតខំស្វែងរក និងជួប**សម្ភាសន៍បែបសំណេះសំណាល**ជាមួយនឹងស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត ចំនួន ១៩ នាក់ ដែលជាទូទៅ ការមិនបានចុះឈ្មោះបោះឆ្នោត គឺដោយសារមូលហេតុមួយចំនួន ។

| **មូលហេតុដែលស្ត្រីមួយចំនួនមិនបានចុះឈ្មោះបោះឆ្នោត** |
|---|
| អ្នកខ្លះថា បាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយគ្មានសំបុត្រកំណើត និងមានគំនិតថា ខ្លួនមានអាយុច្រើន គិត ថាពិបាកក៏មិនទៅចុះឈ្មោះបោះឆ្នោតតែម្តងទៅ ។ |
| អ្នកខ្លះទៀតថា រវល់នឹងកិច្ចការងារ មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ មិនមានពេលទៅហួសមកហួស គិតថាចាំស្អែកៗរហូតដល់ហួសពេលមិនអាចចុះឈ្មោះបាន។ |
| អ្នកខ្លះថា ដោយសារគាត់ជាជនទុរគត មិនមានឯកសារ ទើបមិនអាចទៅចុះឈ្មោះបោះឆ្នោតបាន |
| អ្នកខ្លះថា ដោយសារ គ្មានអត្តសញ្ញាណប័ណ្ណ ហើយទីទាល់ក្រ មិនចង់ទៅចុះឈ្មោះបោះឆ្នោត ពីព្រោះគិតបញ្ហាជីវភាពផ្ទាល់ខ្លួនជាសំខាន់ជាង។ |
| អ្នកខ្លះថា ដោយបានធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហើយតែមិនទាន់បាន និងកំពុងកូនខ្ចីផង |
| អ្នកខ្លះថា ដោយសារមានជំងឺ ផ្ទះឆ្ងាយ គ្មានអ្នកចាំផ្ទះ |
| អ្នកខ្លះថា មានអត្តសញ្ញាណប័ណ្ណ តែបានប្តូរទីកន្លែងថ្មី ខ្ជិលធ្វើឯកសារផ្ទេរទីលំនៅ និងហាក់មិនចង់ចុះឈ្មោះផង |
| អ្នកខ្លះថា អស់ជំនឿគ្មានការរីកចំរើនអ្វីសោះក្នុងឃុំរបស់ខ្លួន។ |

## ២. ៤. ស្ត្រីជាអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ

*ស្ត្រីអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយជាស្ត្រីដែលចូលរួមសង្កេតការណ៍ក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦នេះ មិនមានការរារាំងទេ* ។ រីឯមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត និងគណបក្សនយោបាយ មានការសហការគ្នា ជួយដល់ប្រជាពលរដ្ឋចុះឈ្មោះ មានការរៀបចំឲ្យតម្រង់ជួរ និងជួយពិនិត្យ ណែនាំ ប្រាប់ពីឯកសារពាក់ព័ន្ធនានា ។

អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយក៏មានសំណូមពរទាក់ទងនឹងដំណើរការចុះឈ្មោះបោះឆ្នោតឲ្យកាន់តែប្រសើរឡើង ដោយសូមឲ្យមានការអប់រំ ផ្សព្វផ្សាយអំពីត័ត៌មានចុះឈ្មោះបោះឆ្នោត និងដំណើរការបោះឆ្នោតឲ្យបានទូលំទូលាយជាងនេះ ជាពិសេសតំបន់ដាច់ស្រយាល ខ្វះចំណេះដឹង កម្មករ កម្មការនីរោងចក្រ និងអ្នកចំណាកស្រុក។

## ២. ៥. ភាពមិនប្រក្រតីក្នុងដំណើរការចុះឈ្មោះបោះឆ្នោត

*តាមរយៈការតាមដាន ឃ្លាំមើល សង្កេតការណ៍ អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលមិនបានរកឃើញមានករណីមិនប្រក្រតីណាមួយទាក់ទិននឹងស្ត្រីទេ* ។ នេះអាចដោយហេតុផល មានមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ និងភ្នាក់ងារគណបក្សចេះសហការគ្នា និងបានណែនាំប្រជាពលរដ្ឋឲ្យចេះយល់អធ្យាស្រ័យគ្នា ព្រមទាំងមានសមត្ថកិច្ចការពារជាប្រចាំផងដែរ។

ទោះជាយ៉ាងណាក៏ដោយ យើងឃើញមានការខកខានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការចុះឈ្មោះបោះឆ្នោត ដូចជា ចាស់ជរា ស្ត្រីទើបសម្រាលកូន ពិការជន ដែលមិនមានក្រុមចល័តទៅចុះឈ្មោះបោះឆ្នោតដល់ផ្ទះ ឬទីកន្លែងរបស់ពួកគាត់ និងអ្នកផ្លាស់ប្តូរទីលំនៅ ឬទៅតាមប្តី-ប្រពន្ធ ប្តូរទីកន្លែងធ្វើការ ជាពិសេស កម្មករកម្មការិនីចំណាកស្រុកទៅក្រៅប្រទេស ដែលមិនមាននីតិវិធីសម្របសម្រួលណាមួយ ឲ្យពួកគាត់បានអនុវត្តសិទ្ធិរបស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញបានធានាអំពីសិទ្ធិនេះ ។

## ២. ៦. ការអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោត

ការអប់រំអ្នកបោះឆ្នោត ពិតជាដើរតួនាទីដ៏សំខាន់ក្នុងការផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីដំណើរការចុះឈ្មោះបោះឆ្នោត អំពីសារៈសំខាន់នៃការចុះឈ្មោះបោះឆ្នោត និងអំពីដំណាក់កាលនីមួយៗនៃការបោះឆ្នោត ប្រយោជន៍ឲ្យម្ចាស់ឆ្នោតមានការយល់ដឹងកាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយអំពីការបោះឆ្នោត និងមានការចូលរួមច្រើនជាអតិបរមា ។

ជាក់ស្តែងការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការអប់រំអ្នកបោះឆ្នោតត្រូវធ្វើជាសាធារណៈតាមក្រុមគោលដៅ ដោយត្រូវចាប់ផ្តើមតាមកាលកំណត់សមស្របមួយមុនបើកការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ។ នៅក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត បានកំណត់អំពីកាតព្វកិច្ចរបស់គ.ជ.បក្នុងការផ្តល់ព័ត៌មានឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទាក់ទងនឹងដំណើរការចុះឈ្មោះបោះឆ្នោត ដោយមានការសហការជាមួយអង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។

*ខាងក្រោមនេះ គឺជាប្រការមួយចំនួនទាក់ទងនឹងការងារបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត និងការងារព័ត៌មានសាធារណៈ ៖*

ប្រការ ២.១. គ.ជ.ប ត្រូវធ្វើការបណ្តុះបណ្តាល ការអប់រំអ្នកបោះឆ្នោត និងការផ្សព្វផ្សាយព័ត៌មានអំពីការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ។

២.១.១ នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត ត្រូវរៀបចំផែនការ ប្រតិទិន និងចាត់ចែងធ្វើការបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតទៅតាមដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត ។

២.១.២ ការអប់រំអ្នកបោះឆ្នោត ត្រូវធ្វើជាសាធារណៈតាមក្រុមគោលដៅ ដោយត្រូវចាប់ផ្តើមតាមកាលកំណត់សមស្របមួយ មុនបើកការចុះឈ្មោះបោះឆ្នោតរហូតដល់ចប់ការចុះឈ្មោះបោះឆ្នោត ។

២.១.៣ សម្ភារអប់រំអ្នកបោះឆ្នោត រួមមាន ផ្ទាំងរូបភាព ស្ប៊ូតអប់រំ រឿងខ្លី ចម្រៀង ការណែនាំពីការចុះឈ្មោះបោះឆ្នោត សម្ភារបោះពុម្ព បដា ដែលត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេង ។

២.១.៣.១ គ.ជ.ប ត្រូវចាត់ធ្វើការផ្សព្វផ្សាយតាមមេក្រូចល័តនៅគ្រប់ឃុំ សង្កាត់មុនថ្ងៃបើកការចុះឈ្មោះបោះឆ្នោត និងមុនការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

២.១.៣.២ គ.ជ.ប ត្រូវធ្វើលិខិតអញ្ជើញអ្នកមានសិទ្ធិបោះឆ្នោតឲ្យមកចុះឈ្មោះបោះឆ្នោត ។

២.១.៤ នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈមានតួនាទីធ្វើការងារទំនាក់ទំនងស្ថាប័នជាតិ អន្តរជាតិ ទាក់ទងនឹងកិច្ចការបោះឆ្នោត និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតជូនសាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការងារបោះឆ្នោត តាមគ្រប់មធ្យោបាយផ្សេងៗ ។

២.១.៤.១ ត្រូវសហការ និងផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ និងឯកជន ដើម្បីឲ្យប្រព័ន្ធផ្សព្វផ្សាយទាំងនោះ ជួយផ្សព្វផ្សាយព័ត៌មានបានទូលំទូលាយ ។

២.១.៤.២ ផលិតសម្ភារអប់រំសម្រាប់ផ្សព្វជាសាធារណៈនូវរូបភាព វីដេអូ សំឡេងជាស៊ីឌី (CD) ឬអឹមភីស្រី (MP3) និងឯកសារបោះពុម្ពផ្សេងៗទៀតសម្រាប់ផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ជនបទ

២.១.៤.៣ ផលិតកម្មវិធីស្វែងយល់អំពីការចុះឈ្មោះបោះឆ្នោត តាមប្រធានបទសំខាន់ៗ ដោយអញ្ជើញសមាជិកគ.ជ.ប និងមន្ត្រីជំនាញធ្វើការបកស្រាយ ដើម្បីផ្សព្វផ្សាយជាសាធារណៈ ។

២.១.៤.៤ ផលិតបទយកការណ៍ ធ្វើសម្ភាសពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត

២.១.៤.៥ ផលិតឯកសារផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោត ការបោះពុម្ពព្រឹត្តិបត្រព័ត៌មាន ខិត្តបណ្ណ និងបណ្ណប្រកាស សេចក្តីជូនដំណឹង ផ្សព្វផ្សាយតាមគ្រប់មធ្យោបាយផ្សេង។

២.១.៤.៧ បង្កើតបណ្តាញព័ត៌មានសង្គមរបស់គ.ជ.ប ដើម្បីផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតឲ្យបានទូលំទូលាយ និងប្រមូលព័ត៌មានពីសាធារណជនមកវិញពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ។

២.១.៤.៨ ធ្វើទំនាក់ទំនង និងផ្លាស់ប្តូរព័ត៌មានជាប្រចាំជាមួយភាគីពាក់ព័ន្ធ ។

២.១.៤.១១ ធ្វើទំនាក់ទំនង និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការងារអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីការបោះឆ្នោត ដើម្បីជំរុញការងារអប់រំសាធារណជនឲ្យបានទូលំទូលាយដល់ជនបទដាច់ស្រយាល ។

២.១.៥ គ.ជ.ប ត្រូវសហការ និងផ្តល់ការគាំទ្រដល់ភាគីពាក់ព័ន្ធ ដែលរួមមាន ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីអប់រំអ្នកបោះឆ្នោត ។

ក្នុងរយៈពេល៣ខែនៃការចុះឈ្មោះបោះឆ្នោត យើងរកឃើញថា **១ខែដំបូង**គ.ជ.បបានខិតខំធ្វើសកម្មភាពអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោតយ៉ាងផុលផុស និងទូលំទូលាយដោយប្រើប្រាស់ឯកសារជាច្រើនប្រភេទដូចជា **(១)បទបញ្ញា និងនីតិវិធី សម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ។ (២) គំរូការិយាល័យបោះឆ្នោត ឆ្នាំ២០១៦ ។ (៣) ឯកសារសម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ។ (៤) ខិតប័ណ្ណ ស្តីពី ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ។ (៥)សូមអញ្ជើញប្រជាពលរដ្ឋទៅ**

**ចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ និងកាលបរិច្ឆេទនៃការចុះ ឈ្មោះ** និង(៦) **ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦** ។ ឯកសារទាំងនេះ ត្រូវបានគ.ជ.បធ្វើការផ្សព្វផ្សាយតាមវិធីសាស្ត្រផ្សេងៗគ្នា ដូចជា ចែក/បិទ និងផ្សព្វផ្សាយតាមភូមិ ឃុំ-សង្កាត់ ។ ចែកតាមក្រុមចុះឈ្មោះបោះឆ្នោតដោយចងកាត់ទទឹងផ្លូវ រួមទាំងការផ្សព្វផ្សាយតាមវិទ្យុ និងមានការចាក់ផ្សាយស្ប៉តអប់រំតាមទូរទស្សន៍មួយចំនួន ។ ជាមួយគ្នានេះ អង្គការសង្គមស៊ីវិលមួយចំនួន និងគណបក្សនយោបាយក៏បានខិតខំធ្វើការអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋផងដែរ ។

តាមរយៈការឃ្លាំមើល និងសង្កេតដោយយកចិត្តទុកដាក់របស់អង្គការសង្គមស៊ីវិលបានរកឃើញថា ២ខែចុងក្រោយ សកម្មភាពអប់រំផ្សព្វផ្សាយផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋទូទាំងប្រទេសអំពីការចុះឈ្មោះបោះឆ្នោត គឺពុំសូវមានភាពសកម្ម និងមានការថយចុះខ្លាំងទាំងគ.ជ.បខ្លួនឯង ទាំងអង្គការសង្គមស៊ីវិល ទាំងគណបក្សនយោបាយ ។ អង្គការសង្គមស៊ីវិល មានការព្រួយបារម្ភចំពោះចំនួនអ្នកចុះឈ្មោះបោះឆ្នោតដែលធ្លាក់ចុះក្រោមការរំពឹងទុក ១០ម៉ឺននាក់ក្នុងមួយថ្ងៃចាប់ពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦មក[4] ព្រមទាំងមានការរារាំងខ្លះៗពីសំណាក់អាជ្ញាធរដែនដីចំពោះគណបក្សនយោបាយដែលបាន និងកំពុងធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយកន្លងមក ។ ដោយសារមើលឃើញបែបនេះ ក្រុមអង្គការសង្គមស៊ីវិលបានផ្ញើលិខិតចំហរទៅ **ឯកឧត្តម ស៊ិក ប៊ុនហុក** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងគោលបំណងស្នើ**បន្ថែមយុទ្ធនាការឲ្យរឹតតែខ្លាំង និងផុលផុសក្នុងការអប់រំ ផ្សព្វផ្សាយទាំងគ.ជ.ប អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ ដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦នេះ ។**

ក្នុងលិខិតចំហរនេះ អង្គការសង្គមស៊ីវិលបានស្នើទៅគ.ជ.បចំនួន ២ចំណុច ៖

*១. សូម គ.ជ.ប បើកកិច្ចប្រជុំពិភាក្សាបន្ទាន់ជាមួយអ្នកពាក់ព័ន្ធមួយចំនួនរួមមាន ប្រព័ន្ធផ្សព្វផ្សាយ គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលដែលកំពុងធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោត ដើម្បីជំរុញឲ្យមានយុទ្ធនាការអប់រំ ផ្សព្វផ្សាយរួមគ្នាយ៉ាងផុលផុសទូទាំងប្រទេស ប្រយោជន៍ជម្រុញប្រជាពលរដ្ឋដែលគ្រប់អាយុបោះឆ្នោត ទៅចុះឈ្មោះបោះឆ្នោតឲ្យបានគ្រប់ៗគ្នាតាមផែនការដែលបានគ្រោងទុក ។*

*២. សូមគ.ជ.ប ចេញនូវលិខិតអន្តរាគមន៍ជាបន្ទាន់ទៅអាជ្ញាធរដែនដី/មូលដ្ឋានដើម្បីសម្របសម្រួលដល់អ្នកពាក់ព័ន្ធផ្សេងៗជាពិសេស គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលក្នុងការធ្វើសកម្មភាពយុទ្ធនាការអប់រំ ផ្សព្វផ្សាយផ្តល់ព័ត៌មានឲ្យបានកាន់តែទូលំទូលាយអំពីការចុះឈ្មោះបោះឆ្នោត និងសារៈសំខាន់នៃការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួននៅថ្នាក់មូលដ្ឋាន ។*

[4] របាយការណ៍សង្ខេបលើកទី១របស់ខុមហ្វ្រែល ស្តីពី «ការសង្កេតដំណើរការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦» (សង្កេតចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦)

ឆ្លើយតបនឹងលិខិតចំហរនេះ គ.ជ.បបានសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងខិតខំអន្តរាគមន៍ជាមួយអាជ្ញាធរដែនដី ព្រមទាំងបានផ្គត់ផ្គង់ឯកសារអប់រំមួយចំនួនដល់ក្រុមយុវជនសម្រាប់ធ្វើយុទ្ធនាការពិសេសអប់រំ ផ្សព្វផ្សាយក្នុងអំឡុងពេលព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែរយៈពេល៣ថ្ងៃ ។ ប៉ុន្តែអ្វីដែលគួរឲ្យសោកស្តាយបំផុតនោះ គឺថា គ.ជ.បមិនអាចការពារយុទ្ធនាការអប់រំ ផ្សព្វផ្សាយជាមួយការប្រើប្រាស់ឧបករណ៍បំពងសម្លេងដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត បើទោះបីមានលិខិតអនុញ្ញាតរបស់សាលារាជធានីភ្នំពេញ ដីការអមលេខ ១០១៣/១៦ដែលជម្រាបជូនទៅអភិបាលនៃគណៈអភិបាលខណ្ឌទាំង១២ក្នុងរាជធានីភ្នំពេញក៏ដោយ ។

### ខាងក្រោមនេះជាសកម្មភាពអប់រំ ផ្សព្វផ្សាយ និងករណីកើតឡើង ៖

- ក្រុមយុវជន និងប្រជាពលរដ្ឋប្រមាណ៧០នាក់នៅឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការចុះឈ្មោះបោះឆ្នោត ។ យុទ្ធនាការនេះ រៀបចំឡើងដោយមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center)ក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប នៅព្រឹកថ្ងៃទី២៦ ខែកញ្ញា ។ គោលបំណងយុទ្ធនាការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការចុះឈ្មោះបោះឆ្នោតនេះ គឺដើម្បីជម្រុញយុវជន និងពលរដ្ឋទាំងអស់ដែលគ្រប់អាយុចុះឈ្មោះបោះឆ្នោតឲ្យពួកគាត់បានចុះឈ្មោះគ្រប់ៗគ្នា ។ យុវជន និងប្រជាពលរដ្ឋយល់ថា ការចុះឈ្មោះបោះឆ្នោតគឺពិតជាមានសារៈសំខាន់សម្រាប់ពួកគេ ព្រមទាំងប្រជាជនខ្មែរផ្សេងទៀត ពីព្រោះពួកគេអាចមានសិទ្ធិគ្រប់គ្រាន់ក្នុងការបោះឆ្នោតជ្រើសរើសបុគ្គលដែលខ្លួនពេញចិត្តសម្រាប់ដឹកនាំសហគមន៍ ឬប្រទេសជាតិរបស់ខ្លួន ។

#### *ករណីបានកើតឡើងមួយចំនួនក្នុងពេលអប់រំ ផ្សព្វផ្សាយក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ៖*

មានការរារាំងពីអាជ្ញាធរ និងមិនមានការលើកទឹកចិត្តពេញលេញពី គ.ជ.ប ចំពោះសកម្មភាពអប់រំ ផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតពីគណបក្សក្រៅរដ្ឋាភិបាល ។

- រសៀលថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ មេឃុំកំពង់ថ្កូវមកពីគណបក្សប្រជាជនកម្ពុជា ស្រុកក្រឡាញ់ ខេត្តសៀមរាប រួមទាំងសមត្ថកិច្ចបានចុះទៅហាមឃាត់យុវជនរបស់គណបក្សសង្គ្រោះជាតិដែលកំពុងធ្វើការផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត ។

- កាលពីរសៀលថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៦ សមត្ថកិច្ចខេត្តបាត់ដំបង បានរារាំងក្រុមយុវជនរបស់គណបក្សសង្គ្រោះជាតិប្រមាណ១០០នាក់ក្នុងពេលធ្វើយុទ្ធនាការចែកផ្សាយខិត្តបណ្ណ ដើម្បីជម្រុញឲ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតក្នុងពេលប្រជាពលរដ្ឋមកទស្សនាពិធីអុំទូកក្នុងក្រុងបាត់ដំបង ។ ប៉ុន្តែអភិបាលក្រុងបាត់ដំបងបញ្ជាក់ថា ការរារាំងដោយសារតែធ្វើយុទ្ធនាការផ្សព្វផ្សាយនេះក្នុងពិធីបុណ្យដែលប្រពលរដ្ឋមកកំសាន្ត ។ សូមបញ្ជាក់ថា ក្រុមយុវជនគណបក្សសង្គ្រោះជាតិនេះបានដាក់សំបុត្រស្នើសុំផ្សព្វផ្សាយទៅសាលាក្រុងបាត់ដំបង ប៉ុន្តែសាលាក្រុងមិនអនុញ្ញាតិ ។ *តើការមិនអនុញ្ញាតិនេះវាផ្ទុយនឹងច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីរបស់គ.ជ.បដែរឬទេ?*

អង្គការសង្គមស៊ីវិល មានការខកចិត្តយ៉ាងខ្លាំង ចំពោះទង្វើរបស់អាជ្ញាធរដែលបានរំខាន រារាំង និងបង្អាក់ម្តង ហើយម្តងទៀតទៅលើសកម្មភាពអប់រំ ផ្សព្វផ្សាយ អំពីការចុះឈ្មោះបោះឆ្នោត ។ ជាក់ស្តែង ក្រុមយុវជន យុវតី ក្នុងយុទ្ធនាការអប់រំ ផ្សព្វផ្សាយជំរុញប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតនាព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ ដែលជាបុណ្យប្រពៃណីជាតិខ្មែរ។ យុវជន-យុវតី ប្រមាណជាង ៦០នាក់ មកពីអង្គការ PEP-Center, YRDP, KYSD, NICFEC, CPWP, SEPY និង ក្រុមនិសិត្សស្ម័គ្រចិត្តមួយចំនួនទៀតបានជួបបញ្ហាមួយចំនួនក្នុងអំឡុងពេលធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយជំរុញឲ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតរយៈពេល ៣ថ្ងៃ (ថ្ងៃទី១៣-១៤-១៥ ខែវិច្ឆិកា) ដូចជា៖

- អាជ្ញាធរធ្វើការតាមរំខាន រារាំងសកម្មភាពអប់រំ ផ្សព្វផ្សាយនេះ បើទោះបីជាក្រុមយុវជន យុវតីមានលិខិតអនុញ្ញាតរបស់សាលារាជធានីភ្នំពេញ ដីការអមលេខ ១០១៣/១៦ ដែលជម្រាបជូនទៅលោកអភិបាលនៃគណៈអភិបាលខណ្ឌទាំង ១២ក្នុងរាជធានីភ្នំពេញក៏ដោយ។

- មានការបង្ខំ យុវជន-យុវតីទាំងនោះ មិនឲ្យប្រើប្រាស់ឧបករណ៍បំពងសម្លេងជំនួយក្នុងការផ្សព្វផ្សាយជំរុញឲ្យពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត។

- មិនត្រឹមតែប៉ុណ្ណោះ ក្រុមអាជ្ញាធរ កងកម្លាំងសន្តិសុខ បានឃាត់ខ្លួនក្រុមយុវជន យុវតីស្ម័គ្រចិត្តមួយចំនួនប្រមាណអស់រយៈពេលជាងបីម៉ោង ដោយបង្ខំអោយផ្តិតមេដៃបញ្ឈប់សកម្មភាពអប់រំ ផ្សព្វផ្សាយរបស់ខ្លួន និងបានដកហូតទូរស័ព្ទរបស់មេក្រុមចំនួន ២គ្រឿង ទុកមួយរយៈពេល ទាល់តែមានយុវជន-យុវតីទាំងនោះយល់ព្រមផ្តិតមេដៃបញ្ឈប់សកម្មភាពរបស់ខ្លួន ទើបប្រគល់ទូរស័ព្ទដៃឲ្យវិញ ។

ជាមួយគ្នានេះដែរ ក្រុមយុវជនបានរកឃើញបញ្ហាប្រឈមមួយចំនួនរបស់ប្រជាពលរដ្ឋក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ៖

- ប្រជាពលរដ្ឋមួយចំនួនបានត្អូញត្អែរពីការមិនមានអត្តសញ្ញាណប័ណ្ណដោយពួកគេបានបញ្ជាក់ថា ពួកគេគ្រប់អាយុហើយនៅតែមិនទាន់មានអត្តសញ្ញាណប័ណ្ណ ហើយអាជ្ញាធរហាក់មិនខ្វាយខ្វល់ចំពោះការស្នើរសុំធ្វើអត្តសញ្ញាណប័ណ្ណរបស់ពួកគេ។ ជាក់ស្តែង យុវជនឈ្មោះ សិលា អាយុ២១ ឆ្នាំ មានកំណើតនៅភូមិតាលូ ឃុំតាលូ ស្រុកបាកាន ខេត្តពោធិ៍សាត់ បានពោលប្រាប់ថា៖ ខ្លួនបានបាត់អត្តសញ្ញាណប័ណ្ណ ហើយខ្លួនបានប្តឹងទៅអាជ្ញាធរមូលដ្ឋាន និងសុំបំពេញបែបបទធ្វើអត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរថ្មី ប៉ុន្តែច្រើនខែកន្លងទៅការរំពឹងចាំរបស់ខ្លួនគឺមិនមានលទ្ធផលអ្វីសោះ ។ ចុងក្រោយខ្លួនសុខចិត្តយកសំបុត្រកំណើត ដើម្បីទៅសុំលិខិតបញ្ជាក់អត្តសញ្ញាណដើម្បីមានសិទ្ធិសុំចុះឈ្មោះបោះឆ្នោត ។

- មានប្រជាពលរដ្ឋប្រមាណជាង៣០%ឆ្លើយថា៖ ខ្លួនមិនយល់ពីលក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោតរួមទាំងអ្នកបានចុះឈ្មោះរួចហើយក្តី (អ្នកខ្លះឆ្លើយថាខ្លួនទៅចុះឈ្មោះទាំងមិនដឹងលក្ខខណ្ឌឯកសារទាមទារ)។ ខ្លះទៀតបានត្អូញត្អែរថា មិនទាន់ទទួលបានព័ត៌មានច្បាស់លាស់ និងលក្ខខណ្ឌបែបណាដើម្បីមានសិទ្ធិទៅចុះឈ្មោះបោះឆ្នោតបាន។

- ប្រជាពលរដ្ឋ និងអាជីវករមួយចំនួនប្រាប់ថា៖ ពួកគាត់រវល់ពេកមិនទាន់បានទៅចុះឈ្មោះនៅឡើយ ហើយគាត់សន្យាថានឹងទៅចុះឈ្មោះក្រោយចប់បុណ្យអុំទូក។

- ក្រុមយុវជនផ្សព្វផ្សាយបានរកឃើញថា យុវជនប្រមាណ១០០នាក់ មានយុវជន៥នាក់ បានឆ្លើយថាពួកគាត់មិនបានដឹងអ្វីសោះពីការចុះឈ្មោះបោះឆ្នោតថ្មី ។

- អាជ្ញាធរធ្វើអត្តសញ្ញាណប័ណ្ណមានភាពយឺតយ៉ាវ

- មានលោកអ៊ំចាស់ម្នាក់គាត់បាននិយាយថា « មេឃុំមិនត្រូវជាមួយគាត់ ។ ដូច្នេះគេមិនធ្វើលិខិតបញ្ជាក់អត្តសញ្ញាណឲ្យគាត់បានទៅចុះឈ្មោះបោះឆ្នោតនោះទេ (ឃុំព្រៃស្នា ស្រុកព្រះស្តេច ខេត្តព្រៃវែង) » ។

## ៣. ចំនួនស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦

### ៣. ១. ស្ត្រីបានចុះឈ្មោះបោះឆ្នោត

| ចំនួន ឃុំ សង្កាត់ | ចំនួនអ្នកបានចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ | | | |
|---|---|---|---|---|
| | ចំនួនសរុប ប្រុស-ស្រី | | ចំនួនស្ត្រី | |
| | ចំនួន | % | ចំនួន | %ស្ត្រី |
| ១៦៣៣ | ៧ ៨៦៥ ០៣៣ | ៨១,៣៨% | ៤ ២១០ ៩១៤ | ៥៣,៥៣% |

*(សូមមើលព័ត៌មានលម្អិតនៅក្នុងឧបសម្ព័ន្ធ)*

### ៣. ២. ស្ត្រីជាអ្នកសង្កេតការណ៍ចុះឈ្មោះបោះឆ្នោត[5]

**ស្ត្រីជាអ្នកសង្កេតការណ៍ជាតិ**

| ចំនួន សមាគម អង្គការ | ចំនួនអ្នកសង្កេតការណ៍ជាតិ | | | | | |
|---|---|---|---|---|---|---|
| | សរុប (ប-ស) | ស្ត្រី | %ស្ត្រី | ចល័ត (ប-ស) | ស្ត្រី | %ស្ត្រី |
| ១៣ | ២ ៨៣០ | ១ ០៤៥ | ៣៦,៩២% | ៥៩ | ១០ | ១៦,៩៥% |

[5] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញផ្សាយជាសាធារណៈនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ អំពី «អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិចូលរួមពិនិត្យមើលដំណើរការចុះឈ្មោះបោះឆ្នោត»

### ស្ត្រីជាអ្នកសង្កេតការណ៍អន្តរជាតិ

| ចំនួន សមាគម អង្គការ | ចំនួនអ្នកសង្កេតការណ៍ជាតិ | | |
|---|---|---|---|
| | សរុប (ប-ស) | ស្ត្រី | %ស្ត្រី |
| ៣ | ៣៤ | ១៤ | ៤១,១៧% |

*(សូមមើលព័ត៌មានលម្អិតនៅក្នុងឧបសម្ព័ន្ធ)*

### ៣. ៣. ស្ត្រីជាភ្នាក់ងារគណបក្សនយោបាយចូលរួមពិនិត្យមើលដំណើរការចុះឈ្មោះបោះឆ្នោត[6]

| ចំនួនគណបក្សនយោបាយ | ពេញសិទ្ធិ | | | បម្រុង | | | សរុបពេញសិទ្ធិ និងបម្រុង | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | %ស្ត្រី | សរុប | ស្ត្រី | %ស្ត្រី | សរុប | ស្ត្រី | %ស្ត្រី |
| ១០ | ៦ ៦១៩ | **៦៦៥** | ១០,០៤% | ៧ ០៣៥ | ១ ០៥០ | ១៤,៩២% | ១៣ ៦៥៤ | **១ ៧១៥** | **១២,៥៦%** |

មានភ្នាក់ងារគណបក្សនយោបាយចូលរួមពិនិត្យមើលដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ នៅតាមសាលាឃុំ សង្កាត់១៦៣៣ ទូទាំងប្រទេស សរុបចំនួន **១៣ ៦៥៤នាក់** (ទាំងពេញសិទ្ធិ និងបំរុង) ក្នុងនោះ ស្ត្រីចំនួន **១ ៧១៥នាក់** ស្មើនឹង **១២,៥៦%** ដែលមកពីគណបក្សនយោបាយចំនួន ១០។ *(សូមមើលនៅក្នុងឧបសម្ព័ន្ធ ចំនួន និងឈ្មោះគណបក្សនយោបាយនីមួយៗ)*

### ៣. ៤. ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត[7]

| **សរុបរួម** | **ស្ត្រី** | % |
|---|---|---|
| **៦ ១១៧ នាក់** | **១ ២៣១ នាក់** | ២០,១២% |

[6] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញផ្សាយជាសាធារណៈនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ អំពី «ចំនួនភ្នាក់ងារគណបក្ស នយោបាយចូលរួមពិនិត្យមើលដំណើរការចុះឈ្មោះបោះឆ្នោត»

[7] ខុមហ្វ្រែលបានទទួលព័ត៌មានពីគ.ជ.ប អំពី «ចំនួនមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោតទូទាំងប្រទេសសម្រាប់ប្រតិបត្តិការក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦»

## V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

*ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម* ***ច្រើនជាង*** *ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រប្រុសដែលបានចុះបេសកកម្ម* គឺ ៨៣,៣៣% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី២០នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៤នាក់ ច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្រប្រុសចំនួន ៧៨,៧៩% ស្មើនឹង៧៨នាក់ក្នុងចំណោមសមាជិកសភាប្រុស៩៩នាក់។

អ្នកតំណាងរាស្ត្រស្ត្រីទាំង២០នាក់នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា បានធ្វើសកម្មភាពនៅមូលដ្ឋានមានការ**កើនឡើង**ចំនួន **៨៩លើក** ពី **២៥០លើក** ឆ្នាំ២០១៥ ទៅ **៣៣៩លើក** ឆ្នាំ២០១៦ ។

អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន **ច្រើនជាង** តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។ ប៉ុន្តែ បើគិតជាមធ្យមភាគនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រីម្នាក់ៗ រកឃើញថា *អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិក្នុង១នាក់បានចុះមូលដ្ឋានប្រមាណ ៤០លើក* ***គឺមានភាពសកម្មជាង*** *អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាក្នុង១នាក់បានចុះមូលដ្ឋានប្រមាណតែ ១៣លើក ។*

ភាគរយអ្នកតំណាងរាស្ត្រស្ត្រី**មកពីគណបក្សប្រជាជនកម្ពុជា** បានចុះបេសកកម្មមានចំនួន **១០០%** (១៧នាក់ក្នុងចំណោម១៧នាក់) **ច្រើនជាង**ភាគរយរបស់អ្នកតំណាងរាស្ត្រប្រុសនៃគណបក្សរបស់ខ្លួនដែលមានចំនួនតែ**៧២,៥៥%** (៣៧នាក់ក្នុងចំណោម៥១នាក់) ប៉ុណ្ណោះ ។

ផ្ទុយទៅវិញ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ **តិចជាង**ភាគរយរបស់អ្នកតំណាងរាស្ត្រប្រុសនៃគណបក្សរបស់ខ្លួនដែលបានចុះបេសកកម្ម គឺភាគរយស្ត្រីស្មើនឹង **៤២,៨៦%** (៣នាក់ ក្នុងចំណោម៧នាក់) និងភាគរយប្រុសមានចំនួន **៨៥,៤២%** (៤១នាក់ក្នុងចំណោម៤៨នាក់) ។

សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានានៅតែជា* ***សកម្មភាពអាទិភាព*** *និង**សកម្ម** ខណៈដែលការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតែមានភាព* ***មិនសូវសកម្ម****ដដែល ។*

របាយការណ៍សង្ខេបសកម្មភាពការងាររបស់**ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី (កសកនស)** ក្នុង ឆ្នាំ២០១៦*ភាគច្រើន**មិនបានបង្ហាញអំពីលទ្ធផល**នៃកិច្ចប្រជុំ ឬក៏សេចក្តីសម្រេចណាមួយទាក់ទងនឹងការចូលរួមដោះស្រាយបញ្ហាស្ត្រី និងកុមាររបស់កសកនសឡើយ និងពុំបានបង្ហាញឲ្យឃើញអំពីសាមគ្គីភាពនៅក្នុងក្រុមស្ត្រី និងអំពីការប្រឈមអ្វីខ្លះក្នុងពេលប្រតិបត្តិការការងារដែរ ។*

**ឆ្នាំ២០១៦គឺជាឆ្នាំគួរឲ្យភ្ញាក់ផ្អើល ដែលម្ចាស់ឆ្នោតបានផ្តល់ពិន្ទុគាំទ្រខ្ពស់បំផុតទាក់ទងនឹងការបំពេញកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល***ស្តីពីគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួលបានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋាន ។* បើប្រៀបធៀបនឹងឆ្នាំ២០១៥ មានការ**កើនឡើងខ្លាំងប្រមាណជាង៨០%** គឺ ម្ចាស់ឆ្នោត**ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង**ដែលមានចំនួនចន្លោះពី ៨០% ទៅ ១០០%ឆ្នាំ២០១៦ ដែលខុសគ្នាដាច់ស្រឡះពីឆ្នាំ២០១៥ដែលជាភាគរយទាបបំផុត៨,១៤% ខណៈដែលម្ចាស់ឆ្នោត***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច***ក៏មានការ**ធ្លាក់ចុះ**ដែរ ពី ២៧,៦៣%ឆ្នាំ២០១៥ មកត្រឹម ចន្លោះពី ០% ទៅ ២០%ឆ្នាំ២០១៦ ។

**ការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦នេះ** នីតិវិធីមានភាពងាយស្រួល មានសុវត្ថិភាពល្អ មានសន្តិសុខ មានប៉ូលីស និងសមត្ថកិច្ចការពារត្រឹមត្រូវ ។ រីឯក្រុមប្រឹក្សាឃុំ សង្កាត់ក៏មានការយកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋដែរ រាល់ពេលមានបញ្ហាមានកិច្ចអន្តរាគមន៍ទាន់ពេលភ្លាមៗ ។

**៣៨%នៃស្ត្រីដែលជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត**ភាគច្រើនបានទទួលតួនាទីត្រឹមតែជា**ការីកុំព្យូទ័រ និងជំនួយការប្រធាន**ប៉ុណ្ណោះ ។ ចំណែកឯ **៤៦,៦៦%ជាស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ**ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោតថ្មីនេះនៅក្នុង១០ឃុំ សង្កាត់ដែលជាតំបន់គោលដៅរបស់ខុមហ្វ្រែល ។

**ស្ត្រីបានចុះឈ្មោះបោះឆ្នោតថ្មី** ឆ្នាំ២០១៦ក្នុងបញ្ជីបោះឆ្នោតផ្លូវការ ចំនួន **៤ ២១០ ៩១៤នាក់ ស្មើនឹង ៥៣,៥៣%** នៃចំនួនប្រុស-ស្រីដែលបានចុះឈ្មោះ**សរុប ៧ ៨៦៥ ០៣៣នាក់** ។

**មិនមានការរារាំងស្ត្រីអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយជាស្ត្រី**ដែលចូលរួមសង្កេតការណ៍ក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦នេះទេ ។

មានការ**ខកខានប្រើប្រាស់សិទ្ធិរបស់ខ្លួន**ក្នុងការចុះឈ្មោះបោះឆ្នោត ដូចជា ចាស់ជរា ស្ត្រីទើបសម្រាលកូន ពិរុទ្ធជន ដែលមិនមានក្រុមចល័តទៅចុះឈ្មោះបោះឆ្នោតដល់ផ្ទះ ឬទីកន្លែងរបស់ពួកគាត់ និងអ្នកផ្លាស់ប្តូរទីលំនៅ ឬទៅតាមប្តី-ប្រពន្ធ ប្តូរទីកន្លែងធ្វើការ ជាពិសេសកម្មករកម្មការិនីចំណាកស្រុកទៅក្រៅប្រទេសដែលមិនមាននីតិវិធីសម្របសម្រួលណាមួយ ឲ្យពួកគាត់បានអនុវត្តសិទ្ធិរបស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញបានធានាអំពីសិទ្ធិនេះ ។

**១ខែដំបូងនៃការចុះឈ្មោះបោះឆ្នោតថ្មី គ.ជ.បបានខិតខំ**ធ្វើសកម្មភាពអប់រំផ្សព្វ ផ្សាយដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោតយ៉ាងផុលផុស និងទូលំទូលាយដោយប្រើប្រាស់ឯកសារជាច្រើនប្រភេទ និងវិធីសាស្ត្រផ្សេងៗគ្នានៅទូទាំងប្រទេស ខណៈដែល**២ខែចុងក្រោយ** សកម្មភាពអប់រំផ្សព្វផ្សាយទាំងនេះ***ពុំសូវមានភាពសកម្ម* និងមានការថយចុះខ្លាំង**

ទាំងគ.ជ.បខ្លួនឯង ទាំងអង្គការសង្គមស៊ីវិល ទាំងគណបក្សនយោបាយ ។ ជាមួយគ្នានេះដែរ មានការរារាំងខ្លះៗពីសំណាក់អាជ្ញាធរដែនដីចំពោះគណបក្សនយោបាយ និងក្រុមយុវជនដែលធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន ។

**គ.ជ.ប បានសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងខិតខំអន្តរាគមន៍ជាមួយអាជ្ញាធរដែនដី** ព្រមទាំងបានផ្គត់ផ្គង់ឯកសារអប់រំមួយចំនួនដល់ក្រុមយុវជនសម្រាប់ធ្វើយុទ្ធនាការពិសេសអប់រំ ផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋដែលមកកំសាន្តនៅភ្នំពេញក្នុងអំឡុងពេលព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែរយៈពេល៣ថ្ងៃ ។ ប៉ុន្តែគួរឲ្យសោកស្តាយបំផុត គឺ**គ.ជ.បមិនអាចការពារយុទ្ធនាការអប់រំ ផ្សព្វផ្សាយជាមួយការប្រើប្រាស់ឧបករណ៍បំពងសម្លេង**ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត បើទោះបីមានលិខិតអនុញ្ញាតរបស់សាលារាជធានីភ្នំពេញក៏ដោយ ។

## អនុសាសន៍

**១. អាជ្ញាធរគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស** ត្រូវផ្តល់កិច្ចសហការឲ្យបានទូលំទូលាយជាមួយ **គ.ជ.ប អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ** ក្នុងការជម្រុញយុទ្ធនាការអប់រំ ផ្សព្វផ្សាយផ្តល់ព័ត៌មានអំពីការចុះឈ្មោះបោះឆ្នោត ព័ត៌មានជុំវិញការបោះឆ្នោតតាមរយៈការប្រើប្រាស់ឧបករណ៍បំពងសម្លេង ប្រយោជន៍លើកទឹកចិត្តប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតឲ្យបានច្រើនជាអតិបរមា។

**២. បង្កើតក្រុមចុះឈ្មោះចល័ត**ទៅចុះឈ្មោះបោះឆ្នោតដល់ផ្ទះ ឬទីកន្លែងរបស់ពួកគាត់ដើម្បីផ្តល់ឱកាសដល់ចាស់ជរា ស្រ្តីទើបសម្រាលកូន ពិរុទ្ធជនបានចុះឈ្មោះបោះឆ្នោត និងត្រូវមាននីតិវិធីចុះឈ្មោះបោះឆ្នោតពិសេសសម្រាប់កម្មករកម្មការិនីចំណាកស្រុកទៅក្រៅប្រទេស ដើម្បីឲ្យពួកគេបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចុះឈ្មោះបោះឆ្នោតស្របនឹងរដ្ឋធម្មនុញ្ញដែលបានធានាអំពីសិទ្ធិនេះ ។

**៣. ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី (កសកនស)** គួរតែបង្ហាញអំពីលទ្ធផលការងារដែលបានធ្វើ និងការចូលរួមដោះស្រាយបញ្ហាស្ត្រី និងកុមារក្នុងរយៈពេលមួយឆ្នាំក្នុងរបាយការណ៍សកម្មភាពការងាររបស់ខ្លួន រួមទាំងការប្រឈមក្នុងពេលអនុវត្តការងារផងដែរ ។

**៤. តំណាងរាស្ត្រទាំងស្ត្រី ទាំងបុរស**គួរតែបង្ហាញអំពីលទ្ធផលនៃការចុះបេសកកម្មតាមមូលដ្ឋានរបស់ខ្លួនដល់សាធារណជនទូទៅឲ្យបានដឹង ឮទូលំទូលាយ ។

# ផ្នែកឧបសម្ព័ន្ធ

ខុមហ្វ្រែល COMFRE

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្ដាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 883 750
E-mail: comfrel@online.com.kh Website: http://www.comfrel.org

*ភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧*

# លទ្ធផលនៃការសង្កេតដោយសង្ខេប
## ស្ដីពី
## ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖
## សភា និងតំណាងរាស្ត្រស្ត្រី និងស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦

*ការរកឃើញសំខាន់ៗ រួមមាន **(១)**ការចុះមូលដ្ឋាន(ការចុះតាមមណ្ឌល)របស់អ្នកតំណាងរាស្ត្រស្ត្រី **(២)**ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ និង**(៣)**ស្ត្រីចូលរួមក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ។*

### ១. ការចុះមូលដ្ឋាន (ការចុះតាមមណ្ឌល)របស់អ្នកតំណាងរាស្ត្រស្ត្រី

***ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះមូលដ្ឋាន/បេសកកម្ម <u>ច្រើនជាង</u> ភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះមូលដ្ឋាន ។***

***តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន ច្រើនជាង តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។ ប៉ុន្តែតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ មានភាពសកម្មជាង***

មានតំណាងរាស្ត្រចំនួន**៩៨នាក់**(ស្ត្រី ២០នាក់ និងបុរស ៧៨នាក់) ក្នុងនោះ ៥៤នាក់មកពីគណបក្សប្រជាជនកម្ពុជា មាន**ស្ត្រី១៧នាក់** និង៤៤នាក់មកពីគណបក្សសង្គ្រោះជាតិ មាន**ស្ត្រី៣នាក់** ក្នុងចំណោមតំណាងរាស្ត្រសរុប១២៣នាក់ បានចុះមូលដ្ឋានសរុបចំនួន**១៦៦៥លើក ឆ្នាំ២០១៦** (គណបក្សប្រជាជនកម្ពុជាចំនួន ៥៦៤លើក ស្មើនឹង ៣៣,៨៧% និងគណបក្សសង្គ្រោះជាតិចំនួន ១១០១លើក ស្មើនឹង ៦១,១៣%) ។ ចំនួននេះបាន**កើនឡើង**ចំនួន **៥៥៨លើក** គឺពី **១១០៧លើក** ឆ្នាំ២០១៥ មកដល់ **១៦៦៥លើក** ឆ្នាំ២០១៦ ។

***ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះមូលដ្ឋាន/បេសកកម្ម <u>ច្រើនជាង</u> ភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះមូលដ្ឋាន*** គឺ **៨៣,៣៣%** ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី២០នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៤នាក់ ច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន **៧៨,៧៩%** ស្មើនឹង៧៨នាក់ក្នុងចំណោមសមាជិកសភាបុរស

៩៩នាក់ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ភាគរយរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម**បានកើនឡើង** ពី៧០,៨៣%ឆ្នាំ ២០១៥ ទៅ ៨៣,៣៣%ឆ្នាំ២០១៦ ខណៈដែលអ្នកតំណាងរាស្ត្របុរសចុះបេសកកម្មក៏មានការ**កើនឡើងដែរ** គឺពី ៧៧,៧៧%ឆ្នាំ២០១៥ ទៅ ៧៨,៧៩%ឆ្នាំ២០១៦ ។

អ្នកតំណាងរាស្ត្រស្ត្រីទាំង២០នាក់នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា បានធ្វើសកម្មភាពនៅមូលដ្ឋាន សរុបចំនួន **៣៣៩លើក** មានការ**កើនឡើង**ចំនួន **៨៩លើក** ពី **២៥០លើក** ឆ្នាំ២០១៥ ទៅ **៣៣៩លើក** ឆ្នាំ២០១៦ ។

បើប្រៀបធៀប ពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការ**ខុសគ្នាឆ្ងាយ**រវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន**២២១លើក (៦៥,១៩%)** ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋមានចំនួនតែ **១៣លើក (៣,៨៣%)**ប៉ុណ្ណោះ។* តួលេខនេះ នៅតែបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា**<u>នៅតែជាសកម្មភាពអាទិភាព និងសកម្មដដែល</u>** ខណៈដែល**<u>នៅតែមានភាពមិនសូវសកម្មដដែល</u>**ក្នុងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ* បើទោះបីចំណុចនេះជារឿងសំខាន់ក៏ដោយ ។

តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន **ច្រើនជាង** តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។ ជាក់ស្តែង តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចំនួន១៧នាក់ បានខិតខំធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួន**២២០លើក** គឺមានការ**កើនឡើងស្ទើរតែបីដង** ធៀបនឹងឆ្នាំ២០១៥មានចំនួនតែ៨៥លើកប៉ុណ្ណោះ។ ចំណែកឯ តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិចំនួន៣នាក់ ក៏បានខិតខំធ្វើសកម្មភាពកាន់តែខ្លាំងនៅមូលដ្ឋានដែរចំនួន**១១៩លើក**ក្នុងឆ្នាំ២០១៦ ប៉ុន្តែមានការ**ថយចុះ**បើធៀបនឹងឆ្នាំ២០១៥ មានចំនួន១៦៥លើកឯណោះ។

ទោះបីជាយ៉ាងនេះក៏ដោយ បើគិតជាមធ្យមភាគនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រីម្នាក់ៗ រកឃើញថា ***អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ មានភាពសកម្មជាង អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា*** វិញ។ ជាក់ស្តែង អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិក្នុង**១នាក់ បានចុះមូលដ្ឋានប្រមាណ៤០លើក** (៣នាក់ ចំនួន១១៩លើក) រីឯអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាក្នុង**១នាក់បានចុះមូលដ្ឋានប្រមាណតែ១៣លើក** (១៧នាក់ ចំនួន២២០លើក)ប៉ុណ្ណោះ ។

## ២. ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ

| |
|---|
| *ម្ចាស់ឆ្នោត**ពេញចិត្តស្ទើរតែទាំងស្រុង**ទៅលើការបំពេញកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ* |

យោងតាមរបាយការណ៍ឃ្លាំមើលរដ្ឋាភិបាល អាណត្តិទី៥របស់ខុមហ្វ្រែល ម្ចាស់ឆ្នោតចំនួន១៨រាជធានី ខេត្តបានផ្តល់ពិន្ទុរទៅលើការបំពេញកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំទី៣ ក្នុងឆ្នាំ២០១៦ទាក់ទងនឹង«***ការបំពេញ ឬ***

***អនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួលបានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋាន»*** ជាលទ្ធផលបង្ហាញថា ***ឆ្នាំ២០១៦គឺជាឆ្នាំគួរឲ្យភ្ញាក់ផ្អើល ដែលម្ចាស់ឆ្នោតបានផ្តល់ពិន្ទុគាំទ្រខ្ពស់បំផុតទាក់ទងនឹងការបំពេញកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។*** ជាក់ស្តែង បើប្រៀបធៀបនឹងឆ្នាំ២០១៥ ម្ចាស់ឆ្នោតបានផ្តល់ភាគរយខ្ពស់បំផុតក្នុងការ**ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង**ដែលមានចំនួនចន្លោះពី ៨០% ទៅ ១០០%ក្នុងឆ្នាំ២០១៦ ដែល<u>ខុសគ្នាដាច់ស្រឡះ</u>ពីឆ្នាំ២០១៥ដែលមានភាគរយទាបបំផុត គឺ ៨,១៥% គឺ**កើនឡើងខ្លាំងប្រមាណជាង ៨០%** ខណៈដែលម្ចាស់ឆ្នោត***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច***ក៏មានការ**ធ្លាក់ចុះ**ដែរ ពី ២៧,៦៣% ឆ្នាំ២០១៥ មកត្រឹម ចន្លោះពី ០% ទៅ ២០% ឆ្នាំ២០១៦ ។ តួលេខនេះបង្ហាញឲ្យឃើញថា *ការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងកុមារទទួលបានសិទ្ធិជាមូលដ្ឋានពិតប្រាកដ*របស់រាជរដ្ឋាភិបាលកម្ពុជាមានភាព**ប្រសើរជាងមុន** ដែលធ្វើឲ្យម្ចាស់ឆ្នោតចាប់ផ្តើមគាំទ្រ និងពេញចិត្ត ។

## ៣. ស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦

ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួននៅទូទាំងប្រទេស ក្នុងនោះក៏បានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីនៅក្នុងឃុំ សង្កាត់ចំនួន១០ នៅក្នុងស្រុក ខណ្ឌចំនួន៦ និង៦ខេត្ត ក្រុង ដូចជា ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តតាកែវ និងខេត្តព្រះវិហារ **ក្នុងគោលបំណង** *«សិក្សាអំពីការចូលរួមនយោបាយរបស់ស្ត្រីក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ និងផលប៉ះពាល់មកលើស្ត្រី»*។

***<u>ចំនួនស្ត្រីចុះឈ្មោះបោះឆ្នោត និងការយល់ឃើញរបស់ស្ត្រី</u>***

**ស្ត្រីបានចុះឈ្មោះបោះឆ្នោតថ្មី** ឆ្នាំ២០១៦ក្នុងបញ្ជីបោះឆ្នោតផ្លូវការ ចំនួន **៤ ២១០ ៩១៤នាក់ ស្មើនឹង ៥៣,៥៣%** នៃចំនួនប្រុស-ស្រីដែលបានចុះឈ្មោះ**សរុប ៧ ៨៦៥ ០៣៣នាក់** ។ ហើយក៏មិនមានករណីមិនប្រក្រតីណាមួយមកលើស្ត្រីក្នុងការចូលរួមនយោបាយក្នុងដំណើរការចុះឈ្មោះបោះឆ្នោតនេះដែរ ។ ប៉ុន្តែ មានការ**ខកខានប្រើប្រាស់សិទ្ធិរបស់ខ្លួន**ក្នុងការចុះឈ្មោះបោះឆ្នោត ជាពិសេស ពិរុទ្ធជន និងកម្មករកម្មការិនីចំណាកស្រុកទៅក្រៅប្រទេសដែលមិនមាននីតិវិធីសម្របសម្រួលណាមួយ ឲ្យពួកគាត់បានអនុវត្តសិទ្ធិរបស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញបានធានាអំពីសិទ្ធិនេះ ។

**ស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត** បានបង្ហាញហេតុផលមួយចំនួនថា *«ពួកគេទៅចុះឈ្មោះបោះឆ្នោតគឺ ដើម្បីប្រទេសជាតិ ចង់ឲ្យបក្សដែលខ្លួនស្រឡាញ់បានឈ្នះ អភិវឌ្ឍន៍ក្នុងឃុំ សង្កាត់ បំពេញកាតព្វកិច្ចជាពលរដ្ឋ សម្លេងឆ្នោតរបស់ខ្លួនគឺសំខាន់ក្នុងការជ្រើសរើសតំណាងល្អ» ។* ស្ត្រីដែលបានចុះឈ្មោះបោះឆ្នោតបានបញ្ជាក់ទៀតថា ដំណើរការចុះឈ្មោះបោះឆ្នោតថ្មីនេះ មានភាពងាយស្រួលដូចជា មិនរង់ចាំយូរ គ្មានការគំរាមកំហែង មានការយកចិត្តទុកដាក់ជួយសម្រួលពីមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត ទីកន្លែងធំទូលាយ មិនរញ៉េរញ៉ៃដោយមានប៉ូលីសនៅចាំជួយអន្តរាគមន៍ នៅខាងក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ។

ចំណែកឯ **ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត** បានបង្ហាញពីហេតុផលរបស់ខ្លួនថា *« បាត់/គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយគ្មានសំបុត្រកំណើត ខ្លួនមានអាយុច្រើន គិតថាពិបាកក្នុងការទៅចុះឈ្មោះ ។ ខ្លះទៀត រវល់នឹងកិច្ច*

*ការងារ មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ទីទាល់ក្រ ជាជនទុរគត មិនមានឯកសារអ្វីទាំងអស់ ។ អ្នកខ្លះទៀត អស់ជំនឿគ្មានការរីកចំរើនអ្វីសោះក្នុងឃុំរបស់ខ្លួន ។ល។ និង ។ល។ »*

***ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត និងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់***

៣៨%នៃស្ត្រីដែលជាមន្ត្រីក្រុមចុះឈ្មោះបោះឆ្នោត (កចប)ភាគច្រើនបានទទួលតួនាទីត្រឹមតែជា**សមាជិកលេខាធិការ** និង**ជំនួយការប្រធាន**ប៉ុណ្ណោះ ។ ហេតុផលរបស់ស្ត្រីកចបទាំងនោះបានចូលរួមធ្វើកិច្ចការចុះឈ្មោះបោះឆ្នោត បង្ហាញថា៖ ស្ត្រីកចបដែលអាចទទួលតួនាទីជាមន្ត្រីកចប ដោយសារគាត់ជានិស្សិត ធ្លាប់ជាគ្រូបង្រៀន ជាមន្ត្រីរាជការ និងធ្លាប់ជាសមាជិកគណៈកម្មការរៀបចំការចុះឈ្មោះបោះឆ្នោត ព្រមទាំងមានសមត្ថភាពក្នុងការវាយកុំព្យូទ័រផងដែរ ។ ជាពិសេសស្ត្រីទាំងនោះចង់មានបទពិសោធក្នុងកិច្ចការបោះឆ្នោត និងចង់ជួយកិច្ចការសង្គម ។

៥៦,៦៦%ជាស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោតថ្មីនេះនៅក្នុង១០ឃុំ សង្កាត់ដែលជាតំបន់គោលដៅរបស់ខុមហ្វ្រែល ។

***ការអប់រំអ្នកបោះឆ្នោត***

**គ.ជ.ប**បានខិតខំធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោត**យ៉ាងផុលផុស និងទូលំទូលាយ**ដោយប្រើប្រាស់ឯកសារជាច្រើនប្រភេទ និងវិធីសាស្ត្រផ្សេងៗគ្នានៅទូទាំងប្រទេស ខណៈដែល**២ខែចុងក្រោយ** សកម្មភាពអប់រំផ្សព្វផ្សាយទាំងនេះ**ពុំសូវមានភាពសកម្ម និងមានការថយចុះខ្លាំង ។** ជាមួយគ្នានេះដែរ មានការរារាំងខ្លះៗពីសំណាក់អាជ្ញាធរដែនដីចំពោះគណបក្សនយោបាយ និងក្រុមយុវជនដែលធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន ។

ទន្ទឹមនឹងនេះ **គ.ជ.បបានសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងខិតខំអន្តរាគមន៍ជាមួយអាជ្ញាធរដែនដី** ព្រមទាំងបានផ្តត់ផ្គង់ឯកសារអប់រំមួយចំនួនដល់ក្រុមយុវជនក្នុងយុទ្ធនាការពិសេសអប់រំ ផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែរយៈពេល៣ថ្ងៃ ។ ប៉ុន្តែគួរឲ្យសោកស្តាយ **គ.ជ.បមិនអាចការពារយុទ្ធនាការពិសេសនេះជាមួយការប្រើប្រាស់ឧបករណ៍បំពងសម្លេង**ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត បើទោះបីមានលិខិតអនុញ្ញាតរបស់សាលារាជធានីភ្នំពេញក៏ដោយ ។

***ស្ថានភាពគណបក្សនយោបាយនៅឃុំ សង្កាត់***

ទាក់ទិននឹងស្ថានភាពគណបក្សនយោបាយ អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលបានរកឃើញថា ជាទូទៅមានវត្តមានគណបក្សនយោបាយចន្លោះពី ២ ទៅ ៦គណបក្សនៅក្នុងឃុំ សង្កាត់ទាំង១០នេះដូចជា ៖ គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ គណបក្សសម រង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សខ្មែរជួយខ្មែរ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ។ល។ ប៉ុន្តែ គណបក្សដែលមានទីស្នាក់ការនៅក្នុងឃុំ សង្កាត់ មានតែ ២ ទៅ ៣ គណបក្សប៉ុណ្ណោះ ។ ជាក់ស្តែង មានតែគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖*

១. **លោកស្រីសឺនកេត សិរីលក្ខណ៍** អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រខុមហ្វ្រែល

២. **លោក គីម ឈន** អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធីខុមហ្វ្រែល

# ខុមហ្វ្រែល៖ ក្រុមតំណាងរាស្ត្រស្ត្រីបក្សប្រឆាំងចុះមូលដ្ឋានសកម្មជាងបក្សប្រជាជន

ដោយ រាជ វិញ្ញ (RFA)
2017-04-27




*មន្ត្រីសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល (COMFREL) អ្នកស្រី* ***សឺនកេត សិរីលក្ខណ៍*** *(កណ្ដាល) ក្នុងសន្និសីទសារព័ត៌មានស្ដីពីរបាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧។*

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល (COMFREL) រកឃើញថា នៅឆ្នាំ២០១៦ ក្រុមតំណាងរាស្ត្រស្ត្រីរបស់គណបក្សប្រជាជនកម្ពុជា បានចុះទៅមូលដ្ឋានច្រើនជាងតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ។ ទោះជាយ៉ាងនេះក្ដី ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រស្ត្រីបក្សប្រឆាំង បែរជាមានភាពសកម្មជាងតំណាងរាស្ត្រស្ត្រីមកពីគណបក្សកាន់អំណាច។

អង្គការខុមហ្វ្រែលបានរកឃើញថា ក្នុងចំណោមតំណាងរាស្ត្រសរុប ១២៣នាក់ គឺមានតែ ៩៨នាក់ដែលមកពីគណបក្សប្រជាជនកម្ពុជា មានចំនួន ៥៩នាក់ មានស្ត្រី ១៧នាក់ និងមកពីគណបក្សសង្គ្រោះជាតិ មានចំនួន ៤៤នាក់ មានស្ត្រី ៣នាក់ បានចុះមូលដ្ឋានចំនួន ១.៦៦៥លើកក្នុងឆ្នាំ២០១៦។ ការចុះមូលដ្ឋានក្នុងឆ្នាំ២០១៦ នេះ បានកើនឡើងចំនួន ៥៥៨លើក បើប្រៀបធៀបកាលពីឆ្នាំ២០១៥។ អង្គការដដែលនេះបង្ហាញថា ចំពោះគណបក្សកាន់អំណាចវិញ ចុះមូលដ្ឋានបានចំនួន ៥៦៤លើកស្មើប្រមាណ ៣៣% (៣៣,៨៧%) គឺតិចជាងតំណាងរាស្ត្របក្សប្រឆាំងដែលចុះមូលដ្ឋានបានចំនួនរហូត ១.១០១លើក ស្មើប្រមាណ ៦១% (៦១,១៣%)។

អង្គការខុមហ្វ្រែលបន្តថា ថ្វីត្បិតតែគណបក្សកាន់អំណាចមានតំណាងរាស្ត្រជាស្ត្រីរហូតទៅដល់ ១៧នាក់ បានចុះទៅមូលដ្ឋាន និងគណបក្សប្រឆាំងតែ ៣នាក់ដែលចុះទៅមូលដ្ឋានក្ដី ប៉ុន្តែការចុះមូលដ្ឋានរបស់តំណាងរាស្ត្រស្ត្រីរបស់បក្សប្រឆាំង គឺមានភាពសកម្មជាង ព្រោះបើគិតជាមធ្យម តំណាងរាស្ត្រស្ត្រីមកពីបក្សប្រឆាំងម្នាក់ បានចុះទៅមូលដ្ឋានចំនួន ៤០លើក គឺច្រើនជាងតំណាងរាស្ត្រស្ត្រីបក្សកាន់អំណាចម្នាក់ ដែលបានចុះទៅមូលដ្ឋានតែ ១៣លើក។

ទោះជាយ៉ាងណា ក្នុងចំណោមនៃការចុះមូលដ្ឋានរបស់ក្រុមតំណាងរាស្ត្រជាស្ត្រី ដើម្បីទៅអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ មានតែចំនួន ១៣លើក ស្មើនឹងជិត ៤% (៣,៨៣%) ប៉ុណ្ណោះ រីឯការចុះទៅសំណេះសំណាល ការចែកអំណោយ និងការសម្ពោធសមិទ្ធផលផ្សេងៗមានចំនួន ២២១លើក ស្មើនឹង ៦៥% (៦៥,១៩%)។

មន្ត្រីសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល អ្នកស្រី សឺនកេត សិរីលក្ខណ៍ ថ្លែងថា ថ្វីត្បិតតែភាគរយនៃការចុះមូលដ្ឋានរបស់ក្រុមតំណាងរាស្ត្រស្ត្រីមានច្រើនជាងភាគរយនៃតំណាងរាស្ត្របុរស ហើយចំនួនស្ត្រីមានការកើនឡើងក្នុងឆាកនយោបាយក្ដី ប៉ុន្តែការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ នៅតែមិនទាន់ផ្ដល់ឱកាសឲ្យស្មើភាពគ្នាជាមួយបុរសនៅឡើយ។ អ្នកស្រីបន្តថា បញ្ហានេះដោយសារពុំទាន់មានច្បាប់ ឬគោលនយោបាយដើម្បីគាំទ្រឲ្យស្ត្រីប្រឡូកក្នុងឆាកនយោបាយ៖ *«ចង់ឲ្យមានការឆ្លាស់គ្នាក្នុងការឈរឈ្មោះរវាងបុរស និងស្ត្រីឲ្យបានច្រើន ព្រោះធ្វើបែបនេះ នឹងធ្វើឲ្យមានមេដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដែលជាស្ត្រី-បុរសមានភាពស្មើគ្នា»។*

ការលើកឡើងនេះ ធ្វើឡើងនៅក្នុងសន្និសីទសារព័ត៌មានស្ដីពីរបាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖ សភា និងតំណាងរាស្ត្រស្ត្រី និងក្រុមពិសេសចូលរួមក្នុងការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ និងការដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រី នៅថ្ងៃទី២៧ មេសា។

របាយការណ៍របស់អង្គការខុមហ្វ្រែល បញ្ជាក់ទៀតថា ស្ត្រីដែលបានចុះឈ្មោះដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នៅថ្ងៃទី៤ មិថុនា ខាងមុខនេះមានចំនួនជាង ៤លាននាក់ (៤.២១៣.៤២៧នាក់) ស្មើនឹង ៥៣% នៃចំនួនអ្នកចុះឈ្មោះបោះឆ្នោតស្ត្រី-បុរសទាំងអស់ជាង ៧ លាននាក់ (៧.៨៧៣.១៩៤នាក់)។ ជាមួយគ្នានេះ អង្គការខុមហ្វ្រែលដែលសហការគ្នាជាមួយក្រុមស្ត្រីងាយរងគ្រោះដីធ្លី ស្ត្រីជនពិការ និងអង្គការលើកកម្ពស់ស្ត្រីមួយចំនួនទៀត នឹងដាក់អ្នកសង្កេតការណ៍ស្ត្រីចំនួន ៣០០នាក់ ដើម្បីតាមដាន និងសង្កេតការណ៍ឃោសនាបោះឆ្នោត ថ្ងៃបោះឆ្នោត និងថ្ងៃរាប់សន្លឹកឆ្នោតនៅក្នុងខេត្ត-ក្រុងចំនួន១១។

នៅពេលខាងមុខ ខុមហ្វ្រែល នឹងបង្ហាញអំពីតួលេខស្ត្រីដែលឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។

ស្ត្រីមានបញ្ហាដីធ្លីនៅតំបន់បឹងកក់ កញ្ញា សុង ស្រីលាភ ថ្លែងថា ការចូលរួមសង្កេតការណ៍បោះឆ្នោតខាងមុខរបស់កញ្ញា គឺដើម្បីឲ្យការបោះឆ្នោតធ្វើឡើងដោយយុត្តិធម៌ និងដើម្បីកុំឲ្យអ្នកនយោបាយឈ្លោះប្រកែកគ្នាក្រោយការប្រកាសលទ្ធផលឆ្នោត៖ *«មួយទៀត គឺចង់ឲ្យប្រជាពលរដ្ឋដឹងថា តើការបោះឆ្នោតក្រុមប្រឹក្សាឃុំ–សង្កាត់ និងការបោះឆ្នោតថ្នាក់ជាតិមានសារសំខាន់អីខ្លះ»*។

ចំណែកអតីតស្ត្រីមានបញ្ហាដីធ្លីនៅបុរីកីឡា និងជាបេក្ខនារីលេខរៀងទីមួយមកពីគណបក្សសង្គ្រោះជាតិនៅក្នុងសង្កាត់មិត្តភាពខណ្ឌ៧មករា អ្នកស្រី រស់ សេងឃាង ថ្លែងថា ប្រសិនបើអ្នកស្រីជាប់ឆ្នោតជាចៅសង្កាត់ អ្វីដែលអ្នកស្រីត្រូវធ្វើ គឺជំរុញឲ្យអាជ្ញាធរដោះស្រាយទុក្ខលំបាករបស់ស្ត្រី និងកុមារដោយយុត្តិធម៌៖ *«គឺប្រឹងប្រែង ដើម្បីជំរុញឲ្យថ្នាក់លើជួយដល់ប្រជាពលរដ្ឋ»*។

មន្ត្រីសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល អ្នកស្រី សឹនកេត សិរីលក្ខណ៍ បញ្ជាក់ថា ប្រសិនបើស្ត្រីត្រូវបានគេបោះឆ្នោតឲ្យធ្វើជាមេឃុំ ឬចៅសង្កាត់ច្រើនដូចបុរស ស្ត្រីដែលជាមេឃុំទាំងនោះ នឹងផ្តោតសំខាន់លើការដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រីដូចគ្នា និងកុមារបានច្រើនជាងមុន។ អ្នកស្រីក៏សង្កេតឃើញថា រយៈពេលកន្លងទៅ ស្ត្រីមានបញ្ហាដីធ្លី និងផ្ទះសម្បែងមួយចំនួនដែលធ្លាប់រងការឈឺចាប់ គឺនៅពេលជាប់ឆ្នោតជាមេឃុំ-ចៅសង្កាត់ ពួកគេបានបំពេញការងារមានប្រសិទ្ធភាពជាងស្ត្រីធម្មតា៕

## Females in government make more provincial trips, according to Comfrel’s Gender Watch report




Fri, 28 April 2017 (Phnom Penh Post)
Kong Meta and Erin Handley

Despite Cambodia having only a handful of female lawmakers, they are more likely to visit local communities than their male counterparts, with opposition female lawmakers in particular far outstripping men, according to Comfrel’s Gender Watch report released yesterday.

The election watchdog’s statistics showed that of 24 female lawmakers, more than 83 percent (20) made provincial trips in 2016, compared to around 78 percent of their 99 male counterparts. Women from both parties each made an average of roughly 14 trips per year, while men averaged 13.

The three female lawmakers from the opposition Cambodia National Rescue Party, however, were far and away the most prolific travellers, statistically speaking, averaging 40 trips apiece to the provinces in a year. They also trounced the men in their own party, who averaged only 18 trips apiece.

For female politicians and gender advocates, the figures reinforced a truth they knew only too well – women in power must work harder than men in the same roles.

“I’m not surprised. We are graded much more strictly, graded not only as to performance, [but] they demand higher education from women,” said opposition lawmaker Mu Sochua. “Before we can get an opportunity we have to fight for that opportunity, and then we have to perform extremely well, and if we don’t then we don’t get another chance.”

She said women often paid closer attention to social issues that demanded provincial ventures, such as health care and education.

But this could be a double-edged sword, in which female lawmakers get shoehorned into “soft issues” stereotypically associated with women and are denied decision-making power.

Keo Chanmoney, a Cambodian People’s Party lawmaker in Kampong Chhnang, said visiting local communities was vital to public life.

“We need to go to meet the community people as much as we can to let them know they are not living alone and we care about them,” she said.

“I don’t care how often the CNRP lawmaker women go or what they are doing, but I really encourage our women to go as much as they can,” Chanmoney added.

Comfrel’s education and gender coordinator, Sonket Sereyleak, said the group “wants to see them prioritise intervention cases rather than the gift-giving and inaugurations, because it could help the villagers’ problems”.

Overall, lawmakers made 1,665 provincial visits last year, up from 1,107 visits in 2015.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**

លេខ ១១៩/១៦ គ.ជ.ប/អគ្គ.ប្រ.ក.ព

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

## អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិចូលរួម ពិនិត្យមើលដំណើរការចុះឈ្មោះបោះឆ្នោត

គិតត្រឹមថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ មានអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិសរុបចំនួន ២,៨៣០នាក់។ អ្នកសង្កេតការណ៍ទាំងនេះត្រូវបាន គ.ជ.ប អនុញ្ញាតដើម្បីចូលរួមសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ នៅតាមសាលាឃុំ សង្កាត់ចំនួន ១៦៣៣ ទូទាំងប្រទេស ។

អ្នកសង្កេតការណ៍ជាតិមកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន១៣ ដូចខាងក្រោម៖

| ល.រ | ឈ្មោះសមាគម អង្គការ | ចំនួនអ្នកសង្កេតការណ៍ | ស្រី | ចល័ត(ស្រី) |
|---|---|---|---|---|
| ១ | អង្គការ COMFREL | ១,០៣៦ | ៣៩៩ | ១០ |
| ២ | សហភាពសហព័ន្ធយុវជនកម្ពុជា ( UYFC ) | ៦០៥ | ១៧៥ | |
| ៣ | សហព័ន្ធសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (C.FHRAD) | ៨៨ | ០៨ | |
| ៤ | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center) | ២៤៣ | ១០២ | ១០(០២) |
| ៥ | សមាគមខ្មែរអូរឆ្លងអភិវឌ្ឍន៍តាមគ្រួសារ ( OKFDA ) | ១១ | ០២ | |
| ៦ | អង្គការសង្គ្រោះអនាគតកុមារខ្មែរ ( SCCF ) | ៦៩ | ៣៣ | ០៣(០១) |
| ៧ | សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ និងថែរក្សាកុមារកំព្រា ស្ត្រីក្រីក្រ ( CO.P.A ) | ១២៦ | ៣២ | ០៦(០២) |
| ៨ | អង្គការប្រជាធិបតេយ្យនិងសិទ្ធិមនុស្សក្នុងប្រតិបត្តិការ(DHRAC) | ១៩៧ | ១០០ | ០៤ |
| ៩ | សហព័ន្ធនិស្សិត បញ្ញាវ័ន្ត ប្រជាធិបតេយ្យកម្ពុជា (CDSIF) | ១៦៩ | ៧១ | ១០(០១) |
| ១០ | អង្គការតម្លាភាព ( TIC ) | ១៩ | ០៦ | ០៥(០២) |
| ១១ | អង្គការសេវាប្រជាធិបតេយ្យ ( D.S.O ) | ១៧០ | ៦១ | ០៥(០១) |
| ១២ | សមាគមយុវជនសេដ្ឋកិច្ចកម្ពុជា (Cambodian Economic Youth Association) | ៧២ | ៣៣ | |
| ១៣ | អង្គការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា ( NICFIC ) | ៦៥ | ២៣ | ០៦(០១) |
| | សរុប | ២,៨៣០ | ១,០៤៥ | ៥៩(១០) |

អ្នកសង្កេតការណ៍អន្តរជាតិមានដូចខាងក្រោម៖

| ល.រ | អង្គការអន្តរជាតិ | ចំនួនអ្នកសង្កេតការណ៍ | ស្រី |
|---|---|---|---|
| ១ | សហភាពអឺរ៉ុបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា(EU) | ០៧ | ០៣ |
| ២ | វិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ(NDI) | ១១ | ០៥ |
| ៣ | USAID | ១៦ | ០៦ |
| | សរុប | ៣៤ | ១៤ |

សូមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh; www.necelect.org.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**

**លេខ** ១២០/១៦ **គ.ជ.ប/អគ្គ.ប្រ.ក.ព**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

## ចំនួនភ្នាក់ងារគណបក្សនយោបាយចូលរួមពិនិត្យមើល ដំណើរការចុះឈ្មោះបោះឆ្នោត

គិតត្រឹមថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ មានភ្នាក់ងារគណបក្សនយោបាយចំនួន ១៣,៦៥៤នាក់ ដែល គ.ជ.ប បានអនុញ្ញាតដើម្បីចូលរួមសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ នៅតាមសាលាឃុំ សង្កាត់ ចំនួន១៦៣៣ ទូទាំងប្រទេស ។

ចំនួនភ្នាក់ងារគណបក្សខាងលើនេះមកពី គណបក្សនយោបាយ ចំនួន ១០ រួមមាន ៖

| ល.រ | ឈ្មោះភ្នាក់ងារគណបក្សនយោបាយ | ពេញសិទ្ធិ | | បម្រុង | | សរុបពេញសិទ្ធិ និងបម្រុង | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | គណបក្សប្រជាជនកម្ពុជា | ២,៣០៣ | ២៥៤ | ២,២៨២ | ៣៨៦ | ៤,៥៨៥ | ៦៤០ |
| ២ | គណបក្សសង្គ្រោះជាតិ | ៣,១២៣ | ២៨៧ | ៣,៧០៤ | ៤៦២ | ៦,៨២៧ | ៧៤៩ |
| ៣ | គណបក្សហ្វ៊ុនស៊ិនប៉ិច | ៥០៨ | ៤៥ | ៤៤៥ | ៧២ | ៩៥៣ | ១១៧ |
| ៤ | គណបក្សខ្មែររួបរួមជាតិ | ៥៩៥ | ៦៤ | ៥១៦ | ១១០ | ១១១១ | ១៧៤ |
| ៥ | គណបក្សអំណាចពលរដ្ឋខ្មែរ | ១៧ | ០៣ | ១៧ | ០៧ | ៣៤ | ១០ |
| ៦ | គណបក្ស សមរង្ស៊ី | ០១ | | ០១ | | ០២ | |
| ៧ | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន | ០១ | | ០១ | | ០២ | |
| ៨ | គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ៦៨ | ១២ | ៦៧ | ១៣ | ១៣៥ | ២៥ |
| ៩ | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ០២ | | ០២ | | ០៤ | |
| ១០ | គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ | ០១ | | | | ០១ | |
| សរុប | | ៦,៦១៩ | ៦៦៥ | ៧,០៣៥ | ១,០៥០ | ១៣,៦៥៤ | ១,៧១៥ |

សូមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh; www.necelect.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## តារាងលទ្ធផលផ្លូវការនៃការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

| កូដ | រាជធានី ខេត្ត | ចំនួន | | ស្ថិតិប៉ាន់ស្មាន | | ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោត | | |
|---|---|---|---|---|---|---|---|---|
| | | ឃុំ សង្កាត់ | ការិ.បោះឆ្នោត | សរុបរួម | ១៨ឆ្នាំឡើង | សរុប | ភាគរយ | ស្ត្រី |
| 01 | បន្ទាយមានជ័យ | 65 | 1,019 | 759,920 | 464,927 | 323,956 | 69.68 | 172,589 |
| 02 | បាត់ដំបង | 102 | 1,566 | 1,201,888 | 765,292 | 527,528 | 68.93 | 278,959 |
| 03 | កំពង់ចាម | 109 | 1,555 | 1,136,252 | 707,011 | 541,721 | 76.62 | 292,977 |
| 04 | កំពង់ឆ្នាំង | 70 | 781 | 553,654 | 330,674 | 290,655 | 87.90 | 160,462 |
| 05 | កំពង់ស្ពឺ | 87 | 1,472 | 849,213 | 523,396 | 475,129 | 90.78 | 258,186 |
| 06 | កំពង់ធំ | 81 | 1,053 | 750,885 | 445,563 | 345,228 | 77.48 | 187,651 |
| 07 | កំពត | 93 | 932 | 699,192 | 441,333 | 345,412 | 78.27 | 185,834 |
| 08 | កណ្តាល | 127 | 1,720 | 1,242,861 | 801,813 | 700,525 | 87.37 | 373,674 |
| 09 | កោះកុង | 29 | 179 | 131,811 | 78,550 | 61,846 | 78.73 | 31,469 |
| 10 | ក្រចេះ | 47 | 501 | 385,059 | 224,548 | 171,520 | 76.38 | 88,046 |
| 11 | មណ្ឌលគិរី | 21 | 122 | 77,959 | 41,195 | 36,797 | 89.32 | 18,022 |
| 12 | រាជធានីភ្នំពេញ | 105 | 2,080 | 1,513,583 | 983,828 | 849,214 | 86.32 | 450,814 |
| 13 | ព្រះវិហារ | 51 | 328 | 223,723 | 131,247 | 115,621 | 88.09 | 59,024 |
| 14 | ព្រៃវែង | 116 | 1,749 | 1,232,975 | 764,836 | 620,995 | 81.19 | 344,575 |
| 15 | ពោធិ៍សាត់ | 49 | 679 | 482,223 | 279,367 | 235,221 | 84.20 | 127,334 |
| 16 | រតនគិរី | 50 | 273 | 182,553 | 96,509 | 87,273 | 90.43 | 42,960 |
| 17 | សៀមរាប | 100 | 1,389 | 1,049,794 | 599,193 | 493,626 | 82.38 | 262,472 |
| 18 | ព្រះសីហនុ | 29 | 280 | 224,977 | 135,787 | 119,362 | 87.90 | 60,810 |
| 19 | ស្ទឹងត្រែង | 34 | 207 | 139,644 | 80,053 | 71,028 | 88.73 | 35,558 |
| 20 | ស្វាយរៀង | 80 | 921 | 626,230 | 390,935 | 328,166 | 83.94 | 180,178 |
| 21 | តាកែវ | 100 | 1,525 | 1,036,721 | 642,059 | 549,599 | 85.60 | 298,311 |
| 22 | កែប | 5 | 63 | 39,250 | 24,776 | 23,050 | 93.03 | 12,028 |
| 23 | ប៉ៃលិន | 8 | 114 | 67,137 | 39,387 | 35,850 | 91.02 | 18,081 |
| 24 | ឧត្តរមានជ័យ | 24 | 361 | 231,858 | 134,314 | 116,643 | 86.84 | 58,265 |
| 25 | ត្បូងឃ្មុំ | 64 | 1,279 | 882,004 | 537,623 | 399,068 | 74.23 | 212,635 |
| សរុប | | 1,646 | 22,148 | 15,721,366 | 9,664,216 | 7,865,033 | 81.38 | 4,210,914 |

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៧
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ស៊ិក ប៊ុនហុក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតចំហ

**សូមគោរពជូន**

**ឯកឧត្តម សុិក ប៊ុនហុក**

**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**កម្មវត្ថុះ** សំណើបន្ថែមយុទ្ធនាការឲ្យរឹតតែខ្លាំង និងផុលផុសក្នុងការអប់រំ ផ្សព្វផ្សាយទាំងគ.ជ.ប អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ ដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦នេះ ។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំជាអង្គការសង្គមស៊ីវិលមានកិត្តិយសសូមជំរាបឯកឧត្តមប្រធានគ.ជ.បមេត្តាជ្រាបថា តាមរយៈការឃ្លាំមើល និងសង្កេតដោយយកចិត្តទុកដាក់របស់យើងខ្ញុំបានរកឃើញថា ការអប់រំ ផ្សព្វផ្សាយផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋទូទាំងប្រទេសអំពីការចុះឈ្មោះបោះឆ្នោតនៅពុំទាន់មានភាពសកម្ម និងខ្លាំងក្លានៅឡើយ ទាំងគ.ជ.បខ្លួនឯង ទាំងអង្គការសង្គមស៊ីវិល ទាំងគណបក្សនយោបាយ ។ អង្គការសង្គមស៊ីវិល មានការព្រួយបារម្ភចំពោះចំនួនអ្នកចុះឈ្មោះបោះឆ្នោតដែលធ្លាក់ចុះក្រោមការរំពឹងទុក ១០ម៉ឺននាក់ក្នុងមួយថ្ងៃចាប់ពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦មក ព្រមទាំងមានការរារាំងខ្លះៗពីសំណាក់អាជ្ញាធរដែនដីចំពោះគណបក្សនយោបាយដែលបាន និងកំពុងធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយកន្លងមក ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ យើងខ្ញុំជាអង្គការសង្គមស៊ីវិលសូមស្នើទៅគ.ជ.បដូចខាងក្រោមនេះ ៖

1

**១**. សូម គ.ជ.ប បើកកិច្ចប្រជុំពិភាក្សាបន្ទាន់ជាមួយអ្នកពាក់ព័ន្ធមួយចំនួនរួមមាន ប្រព័ន្ធផ្សព្វផ្សាយ គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលដែលកំពុងធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោត ដើម្បីជំរុញឲ្យមានយុទ្ធនាការអប់រំ ផ្សព្វផ្សាយរួមគ្នាយ៉ាងផុលផុសទូទាំងប្រទេស ប្រយោជន៍ជម្រុញប្រជាពលរដ្ឋដែលគ្រប់អាយុបោះឆ្នោត ទៅចុះឈ្មោះបោះឆ្នោតឲ្យបានគ្រប់ៗគ្នា តាមផែនការដែលបានគ្រោងទុក ។

**២**. សូមគ.ជ.ប ចេញនូវលិខិតអន្តរាគមន៍ជាបន្ទាន់ទៅអាជ្ញាធរដែនដី/មូលដ្ឋានដើម្បីសម្របសម្រួលដល់អ្នកពាក់ព័ន្ធផ្សេងៗជាពិសេស គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលក្នុងការធ្វើសកម្មភាពយុទ្ធនាការអប់រំ ផ្សព្វផ្សាយផ្តល់ព័ត៌មានឲ្យបានកាន់តែទូលំទូលាយអំពីការចុះឈ្មោះបោះឆ្នោត និងសារៈសំខាន់នៃការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួននៅថ្នាក់មូលដ្ឋាន ។

សូមឯកឧត្តមប្រធានគ.ជ.ប មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

*រាជធានីភ្នំពេញ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦*

**អង្គការសង្គមស៊ីវិលដែលគាំទ្រលិខិតចំហនេះរួមមាន ៖**

| **ល.រ** | **នាមអង្គការសង្គមស៊ីវិល** | **នាមអ្នកចូលរួម** | **លេខទំនាក់ទំនង** |
|---|---|---|---|
| ១ | អង្គការសិលកា និងគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ | លោកស្រី ធីដា ឃឹះ | ០១២ ៨៣៨ ៨៦៨ |
| ២ | គណៈកម្មាធិការខុមហ្វ្រែល | លោក គល់ បញ្ញា | ០១២ ៩៤២ ០១៧ |
| ៣ | | លោកស្រី សឺនកេត សិរីលក្ខណ៍ | ០១២ ៧៧៥ ៦៩៦ |
| ៤ | អង្គការដៃគូអភិវឌ្ឍន៍ | លោកស្រី ប្រុក វ៉ាន់នី | ០១២៥៣៨២០១ |
| ៥ | គណៈកម្មាធិការនិកហ្វិច | លោក សំ គុន្ធាមី | ០១២ ៨២២ ២៧៣ |
| ៦ | សភាយុវជនខ្មែរ | លោក ឡេង តឹមយន | ០១២ ៥០៣ ០០៧ |

2

| | | | |
|---|---|---|---|
| ៧ | កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន | លោក ជាង សុខា | ០១២ ៣៦០ ៤៦៤ |
| ៨ | អង្គការកិច្ចអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព | លោក ម៉ម សម្បត្តិ | ០១២ ៧៧៩ ៧៣៤ |
| ៩ | អង្គការតម្លាភាពកម្ពុជា | លោក ព្រាប កុល | ០១២ ៨៧៧ ៨៣៣ |

3

ខុមហ្វ្រែល COMFREL


ទីស្នាក់ការកណ្តាល ផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ 1145,
ទូរស័ព្ទ: (855-23) 884 150, ទូរសា: (855-23) 883 750

#138, St. 122 , Teuk Laak I, Toul Kork, Phnom Penh, CAMBODIA
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019 ,
Fax: (855) 23 883 750 , Email: comfrel@online.com.kh
Website: www.comfrel.org